ព្រះរាជបណ្ណាល័យកម្ពុជា

# កម្ពុជសុរិយា

## សៀវភៅចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ

ឆ្នាំគម្រប់ពីរ

ខែ ១

ក្រុមជំនុំទំនៀមទំលាប់
COMMISSION DES MŒURS & COUTUMES

ក្រុងភ្នំពេញ

រោងពុម្ពរាជការ គូវែរណើម៉ង្គ

គ្រិ. ឆ្នាំ ១៩២៧

ព. ស. ២៤៧០

អ្នកទទួលខុសត្រូវ ជុំ-មៅ

# សេចក្ដីបញ្ជាក់អំពីការបោះពុម្ពផ្សាយជាលើកទី ២
# នៃ ទស្សនាវដ្ដី កម្ពុជសុរិយា

សៀវភៅដ៏ក្រាស់នេះ ជាកម្រងទស្សនាវដ្ដី "កម្ពុជសុរិយា" ដែលបោះពុម្ពឆ្នាំទី ១ ពី គ.ស. ១៩២៦-២៧ ។

គោលបំណងរបស់យើង ក្នុងការរើយកមកបោះពុម្ពជា ១ សៀវភៅនេះជាថ្មី គឺអាស្រ័យដោយសេចក្ដីយល់ថា សព្វថ្ងៃនេះ មានអ្នកសិក្សាស្រាវជ្រាវខាងអក្សរសាស្ត្រ-វប្បធម៌ជាតិកាន់តែច្រើនឡើង ៗ ។ ជនទាំងនេះ តែងត្រូវការចាំបាច់រកឯកសារចាស់ៗ ដែលមានផ្សាយហើយ យកមកធ្វើការពិនិត្យស្រាវជ្រាវនិងជាការសំអាងហេតុផលផ្សេងៗ ក្នុងស្នាដៃថ្មីរបស់ខ្លួនផង ។ ក្នុងបណ្ដាសៀវភៅអក្សរខ្មែរដែលបោះពុម្ពផ្សាយមុនគេ គឺមានតែទស្សនាវដ្ដី «កម្ពុជសុរិយា» នេះឯង ដែលកាលនោះអស់លោកបណ្ឌិតខ្មែរយើង លោកបានគាត់តែងនិពន្ធអត្ថបទ រៃហូរតាមព្រឹត្តិការណ៍ដែលមានក្នុងសម័យនោះ អាចចាត់ទុកបានជាឯកសារយ៉ាងសំខាន់បំផុត ពុំងាយរកបាន ។ អ្នកស្រាវជ្រាវ អាចរកឃើញជាក់ច្បាស់នូវហេតុការណ៍ដែលកើតមានក្នុងរវាងជាង ៤០ ប្លាយឆ្នាំហើយ ។

ប៉ុន្តែ យើងសូមបញ្ជាក់ថា ការបោះពុម្ពគ្រានេះ យើងរៀបចំប្លែកបន្តិចពីច្បាប់ដើមគឺ ៖

១-តួអក្សរយើងប្ដូរមកជាតួល្អិតវិញ ហើយមានកែទំព័រត្រង់ណាមានចំណងជើងមួយសន្ទឹកផ្សេង យើងក៏ទាញយកមកដាក់ភ្ជាប់ពីលើអត្ថបទ

តែម្តង ។

២-ចំពោះរូបភាព ទាំងអស់ យើងពុំបានបោះឡើងវិញទេ ព្រោះរូបទាំងនោះចាស់ជ្រុលពេក ហើយព្រិល ៗ មិនសូវច្បាស់ យើងពុំអាចយកមកធ្វើពុម្ពជាថ្មីបាន ។

៣- មានអត្ថបទវែងមួយ ដែលមានចុះផ្សាយកាលនោះ ប៉ុន្តែឥឡូវយើងពុំបានបោះឡើងវិញទេ គឺ ៖

" គតិលោក របស់ ឧកញ៉ា សុត្តន្តប្រីជា ឥន្ទ " ។ ហេតុបានជាពុំបានបោះផ្សាយឡើងវិញ ព្រោះយល់ថា ក្នុងឆ្នាំនោះ អត្ថបទនេះឯង ក៏ពុំបានចុះផ្សាយចប់ដែរ ហើយវិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យក៏បានយកអត្ថបទរឿងនេះ មកបោះពុម្ពជាសៀវភៅរួចស្រេចដាក់ជាវជាយូរឆ្នាំមកហើយផង ។ ម្ល៉ោះហើយ អ្នកស្រាវជ្រាវពុំពិបាកនឹងរកទេ ។

ចំណែកពាក្យពេចន៍ និងឃ្លាល្បះ ជាសំនួនវោហាររបស់អ្នកនិពន្ធយើងឥតប៉ះពាល់ឡើយ ទុកនៅតាមលក្ខណៈដើមទាំងស្រុង គ្រាន់តែតម្រូវអក្ខរាវិរុទ្ធ តាមបែបប្រើសព្វថ្ងៃ តែប៉ុណ្ណោះ ។

ដូច្នេះ វិជ្ជាឋានពុទ្ធសាសនបណ្ឌិត្យ សង្ឃឹមថា សៀវភៅនេះ នឹងផ្តល់មធ្យោបាយងាយស្រួល មួយផ្នែកធំ ចំពោះអ្នកសិក្សាស្រាវជ្រាវជាមិនខាន ។

ភ្នំពេញ ថ្ងៃទី ២០ កុម្ភៈ ១៩៧០

អ្នកប្រមូលរូបរួមបោះពុម្ព

**លី-ធាមតេង**

# បញ្ជីរឿង


ទំព័រ

១- សេចក្តីបង្ហាញប្រយោជន៍នៃទស្សនាវដ្តីកម្ពុជសុរិយាដល់សាធារណជន, ព្រះអង្គម្ចាស់ ក្រុមព្រះ នរោត្តម ភាណុវង្ស ទីអគ្គមហាសេនាធិបតិ, អធិបតិ ក្រុមកាន់កាប់ការ រាជការព្រះរាជបណ្ណាល័យ អធិប្បាយ ២៤

២- សេចក្តីសម្គាល់អំពីរូប ព្រះមេត្រីយពោធិសត្វ ដែលតាំងនៅក្នុងព្រះរាជបណ្ណាល័យអ្នកស្រីក្រមុំ ការប៉ឺឡេស ជាអ្នកគ្រប់គ្រងព្រះរាជបណ្ណាល័យអធិប្បាយ . . . . . . . . . ២៦

៣- អនុត្តរិយសុត្ត ព្រះអង្គម្ចាស់សុធារសបានរៀបរៀងជាសម្រាយសុទ្ធ ២៩

៤- រត្នត្រយបូជាព្រះគ្រូវិមលបញ្ញា អ៊ុម ស៊ូរ អាចារ្យ ព្រះរាជបណ្ណាល័យកម្ពុជាបានរៀបរៀង . . . . . . . ៣៩

៥- សេចក្តីដែលអ្នកអង្គម្ចាស់វឌ្ឍឡាយាវង្ស សូត្រជាភាសាបារាំងនូវមុខៗ សពអ្នកអម្ចាស់ សិង្ហរា ក្រុមការ ដុំ ម៉ៅ ធ្វើរាជការនៅព្រះរាជបណ្ណាល័យប្រែជាភាសាខ្មែរ . . . . . . . . ៥៧

៦- ធម្មទេសនាអំពីព្រះនិព្វានរបស់លោក កុំម៉ង់ដង់គួរូបែរត៍ ដែលសម្តែងនៅព្រះរាជបណ្ណាល័យ កាលពីថ្ងៃ ៩ យូវ៉ាំង ឆ្នាំ ១៩២៧ ក្រុមការ ដុំ ម៉ៅ បានស្រង់យកគោលធំៗ សូត្រក្នុង ឱកាសនោះជាមុន ដែលសម្តែងជាភាសាបារាំង . . . . . . . . . ៦៣

៧- ពាក្យកាព្យបុរាណ អំពីសីល ៥ របស់ឧកញ៉ា វង្សាសារពេជ្រនេង. . . . ៦៨

៨- គតិលោក របស់ឧកញ៉ា សុត្តន្តប្រីជាឥន្ទ ត សេចក្តីគ្នាអំពីខែ ១២ នៃ សៀវភៅទស្សនាវដ្តីឆ្នាំទី ១ (មិនបានចុះក្នុងទីនេះទេ ព្រោះមានបោះជាសៀវភៅរួចហើយ)

# សេចក្ដីអធិប្បាយអំពីផលប្រយោជន៍នៃទស្សនាវដ្ដី
# របស់ព្រះអង្គម្ចាស់ក្រុមព្រះ នរោត្ដម ភាណុវង្ស

ក្រុងភ្នំពេញ នៅថ្ងៃច័ន្ទ ១០ កើតខែចេត្រ ឆ្នាំថោះ នៅក្នុងអដ្ឋស័ក ពុទ្ធសករាជ ២៥១៩ ត្រូវនឹងថ្ងៃ ១១ ខែអាព្រីល ឆ្នាំ ១៩៦៧ ។

អំពីផលប្រយោជន៍នៃទស្សនាវដ្ដីកម្ពុជសុរិយា របស់ព្រះរាជបណ្ណាល័យ ក្រុងកម្ពុជាធិបតី ។

តាំងពីបោះទស្សនាវដ្ដីកម្ពុជសុរិយាមកដល់ឥឡូវនេះចូលក្នុង ឆ្នាំគម្រប់ ២ ហើយ ឃើញមានប្រយោជន៍ច្រើន ដោយសេចក្ដីដែលថ្លែងទាំងអស់ សឹងតែពិរោះជាចំណេះជាដំណឹងផ្សេង ៗ អាចនាំឲ្យចម្រើន តម្រិះប្រាជ្ញា អ្នកទាំងឡាយ ដែលមានសេចក្ដីព្យាយាមមើល ហើយបណ្ដាលឲ្យអ្នកទាំងពួងមានចំណង់ខំគិត តាក់តែងសេចក្ដីគ្រប់ដំពូកពីអតីតនិងបច្ចុប្បន្ន សម្ដែងឡើងឲ្យគេបានយល់ក្ដី ចូលជួយជាចំណេះ ជាតម្រិះ ជាគំនិតគិតការផ្សេង ៗ ដោយសុចរិតឲ្យបានសម្រេចដូចសេចក្ដីប្រាថ្នា ដោយហេតុថា ចេះល្អជាងមិនចេះ ហើយស្រុកយើងតាំងពីបានប្រូតិកតូរ៉ាត់បារាំងសែសជាអាណាព្យាបាលជាទីពឹង ក៏បានចេះដឹងលឿនទៅមុខឥតអាក់ យើងគ្រប់គ្នាត្រូវតែយកចិត្តទុកដាក់ខំធ្វើការរបរ និងតាក់តែងសេចក្ដីតាមចំណេះចេះដឹងជូនមកបោះពុម្ពក្នុងទស្សនាវដ្ដី កម្ពុជសុរិយា ឲ្យច្រើនកុំឲ្យ

ធ្វេសប្រហែស ហើយឲ្យសង្វាតរៀនសូត្រមើលជានិច្ច ឲ្យចម្រើនផលប្រយោជន៍ឲ្យកាន់តែច្រើនបរិបូណ៌ឡើង ជាប្រយោជន៍ផ្ទាល់ខ្លួនយើងនិងស្រុកយើង ជាតិយើង ដែលមានពូជពីបុរាណ ចេះសាងដល់ទៅប្រាសាទមានក្បាច់រចនា សុទ្ធសឹងសិលានៅជាចារិកព្រះនគរ សព្វថ្ងៃនេះស្រាប់ ៗ

ចូរអ្នកទាំងឡាយស្វែងរកសេចក្ដីល្អ ដោយនូវចូលចិត្តទិញសៀវភៅទស្សនាវដ្ដីកម្ពុជសុរិយា យកទៅមើលឲ្យច្រើនឡើងទៀត ព្រោះជាពន្លឺឲ្យស្វាងរុងរឿងក្នុងសន្ដានចិត្ត ហើយឲ្យនាំគ្នាចូលមកឲ្យរឿយ ៗ មើលសាស្ត្រាទឹងសៀវភៅជារឿងក្បួនខ្នាត និងខមសក្ការព្រះពុទ្ធរូបដែលមានតម្កល់ទុកជាច្រើន ក្នុងព្រះរាជបណ្ណាល័យក្នុងក្រុងភ្នំពេញ ដើម្បីឲ្យញ៉ាំងនឹងតាំងចិត្តជាបរិសុទ្ធឲ្យបានសម្រេចកុសលសីលទាន នូវមគ្គផលគ្រប់ប្រការទៅអនាគត ។

ក្រុមព្រះនរោត្ដម ភាណុវង្ស ទីអគ្គមហាសេនាធិបតីសិរីអង្គរក្ស
សមុហនាយកអធិបតី ក្រុមប្រឹក្សារាជការព្រះរាជបណ្ណាល័យ

# សេចក្ដីអធិប្បាយ

## របស់អ្នកស្រី ការប៉ុទ្យេស អំពីរូបព្រះមេត្រីយពោធិសត្វ ដែលតាំងនៅក្នុងព្រះរាជបណ្ណាល័យ

## អំពីរូបមេត្រិយពោធិសត្វប៉ែកខាងមហាយាន

យើងគិតឃើញថាជាការមានប្រយោជន៍ គួរតែអធិប្បាយអំពីបែបភាពសណ្ឋានរូបខ្លះឬរបស់អ្វីខ្លះ ដែលជារបស់ ល្អហើយក្រដែលមាននៅក្នុងព្រះរាជបណ្ណាល័យ ដើម្បីឲ្យអស់អ្នកទិញទស្សនាវដ្ដី ដែលគ្មានឱកាសនឹងចូលទៅមើលព្រះរាជបណ្ណាល័យ បានដឹងស្គាល់គ្រប់គ្នា ។

ពេលនេះ យើងចាប់ផ្ដើមពណ៌នារៀបរាប់អំពីរូប ១ ដែលលោកគ្រូវត្តអំពិលទឹក ក្នុងខេត្តកំពង់ឆ្នាំង បានធ្វើអំណោយដល់ព្រះរាជបណ្ណាល័យ កាលពីឆ្នាំ ១៩២៦ រូបនេះជាបែបចម្លាក់ខ្មែរដ៏ប្រសើរ ឆ្លាក់ធ្វើដំណាងពោធិសត្វ ១ អង្គ ក្នុងពុទ្ធសាសនាប៉ែកខាងមហាយាន ហើយដែលក្រឃើញមានក្នុងស្រុកខ្មែរណាស់ ។

រូបនេះមានកម្ពស់ ២៨ សង់ទីម៉ែត្រ ធ្វើពីសម្រិទ្ធពណ៌បៃតងចាស់ ចាំងពន្លឺសម្បុរត្នោត ពោធិសត្វនោះឈរមានដៃ ៤ តាមពិនិត្យបែបដែលគេរចនានោះ ឃើញថារូបនោះមានផ្ទៃមុខមូល ចង្កាតូច, បបូរមាត់ក្រាស់ ប្រមុះតូច, ផ្នត់ក ៣ ជាន់ៗ ស្មាទូលាយលែងខ្លួនទទេ មានសំពត់

ស្លឹកយ៉ាងខ្ចី ពីចង្កេះមកត្រឹមពាក់កណ្ដាលភ្លៅ នាំឲ្យស្គាល់ច្បាស់ ថាជាបែបរចនាខ្មែរសុទ្ធ ដែលគេបានចាប់ផ្ដើមក្នុងគ្រា ដែលសាងប្រាសាទនៅអង្គរ គឺក្នុងកាលដែលគេចាប់សាងប្រាសាទយ៉ាងល្អ ។

បើមើលរូបនោះឲ្យជាក់ទៅ គេនឹងប្រទះឃើញដៃ ៦ ខាងលើនោះលើកឡើង ហើយម្រាមដៃនោះធ្វើទ្រង់វិតក្កមុទ្រសញ្ញា ហើយឯដៃ ២ ខាងក្រោមលា ម្រាមផ្កាឡើងហុចទៅខាងមុខ ធ្វើទ្រង់វរមុទ្រសញ្ញា (យើងមានសេចក្ដីស្ដាយណាស់ ព្រោះរូបនោះកំបុតដៃស្ដាំបាត់ ) ។

នៅគ្រប់បាតដៃទាំងអស់ មានកងចក្រទំហំផ្សេង ៗ គ្នា ហើយនៅកណ្ដាលកងចក្រនោះ មានគ្រឿងសម្គាល់ផ្សេង ៗ សម្រាប់កងចក្រនោះ ។

គេសម្គាល់ឃើញម្យ៉ាងទៀត ថារូបចំនោះមានពុកចង្កាដុះព័ទ្ធតាំងពីជើងសក់ទាំងសងខាង ទៅជួបគ្នានៅក្រោមបបូរមាត់ក្រោម ហើយនៅបបូរមាត់លើមានពុកមាត់យ៉ាងស្ដើង ចុងទាំងសងខាងរាត់ឡើងលើ ឯភ្នែកទាំង ២ ដែលមានរាងដូចជាខ្លួនត្រីនោះ ឃើញនៅជាប់ថ្នាំខ្មៅនៅប្រស្រី និងថ្នាំសនៅកៀនភ្នែកនៅឡើយ ឯត្រចៀកទាំង ២ នោះ មានទងយារ ហើយចោះធ្លុះហើយ ឯសក់នោះព័ទ្ធគួចជាផ្នួងឡើងទៅលើ រាងដូចកំពូលម្កុដតាល ហើយរចនាជាថ្នាក់ ៤ ជាន់ នៅចំពាក់កណ្ដាលពីខាងមុខនៃផ្នួងនោះ មានឆ្លាក់ជាចេតិយតូច ១ តម្កល់លើផ្កាឈូក តែ

ឃើញមានគ្រឿងអលង្ការក្រោយនេះហើយ បានជាគេអាចនឹងស្គាល់បាន ថារូបនេះធ្វើតំណាងអ្វី ។ គឺជារូបមេត្រីយពោធិសត្វនេះហើយ បានជាគេដឹងថា កាលពីពុទ្ធសករាជ ១៤០០ នោះ ស្តេចស្រុកលង្កាបានសាងរូបពោធិសត្វនេះ ១ អង្គយ៉ាងធំ ។

ពោធិសត្វនេះហើយជាតួអង្គព្រះពុទ្ធជាន់ក្រោយ គឺព្រះពុទ្ធដែលមានមហាករុណា ដែលមានសម្តែងក្នុងគម្ពីរហីនយានជាភាសាបាលី តាំងក្នុងគម្ពីរមហាយានជាភាសាសំស្ក្រឹត ថាពោធិសត្វនេះ នឹងចុះមកត្រាស់ក្នុងជម្ពូទ្វីប ជាក្រោយព្រះពុទ្ធអង្គបរិនិព្វានទៅកន្លង ៥០០០ ឆ្នាំ ក្នុងគ្រាឥឡូវលោកនៅ ៗ ឋានតុសិតដែលលោកបានសិក្សាផ្ទាល់ អំពីពុទ្ធឧស្ឋព្រះពោធិសត្វ លោកតែងរមិលមើល ហើយជួយទ្រទ្រង់មនុស្សលោកឲ្យបានសេចក្តីសុខ ព្រមទាំងឧបត្ថម្ភនូវធម៌អាថ៌ទាំងប៉ុន្មាន ដែលព្រះពុទ្ធបានសម្តែង ឲ្យគង់នៅ ។

ឯចេតិយដែលនៅ ៗ ជួនសក់នោះ ជាតំណាងនៃចេតិយដែលមានសពព្រះកស្សបនៅក្នុងនោះ ហើយចេតិយនោះនឹងបើកឯងនៅវេលាដែលព្រះអរិយមេត្រីយយាងចុះមកក្នុងលោក ដើម្បីឲ្យព្រះកស្សបបានថ្វាយនូវសង្ឃាដី ។

# អនុត្តរិយសុត្ត

## ព្រះអង្គម្ចាស់ សុធារស បានរៀបរៀងមកជាសម្រាយសុទ្ធ

---

## ពណ៌នាប្រារព្ធ

អនុត្តរិយសុត្តនេះ ជាពុទ្ធដីកា អញខ្ញុំបានឃើញបែបបុរាណបណ្ឌិតលោកប្រែមកអំពីមគធភាសា ប្រែជាប្រយោគមានបាលីផង សម្រាយផងចម្រុះគ្នា ដែលលោកតែងមកដូច្នេះនោះ ក៏ជាការប្រពៃ ដើម្បីឲ្យអ្នកបរិយត្តិស្គាល់ប្រយោគ, តែអញខ្ញុំយល់ឃើញថាដែលបុរាណាចារ្យលោកតែងមកនោះ ចំពោះដល់តែអ្នករៀនឲ្យយល់សព្ទ មិនជាទីសណ្ដាប់ដល់អ្នកដែលមិនរៀនព្រះត្រៃបិដក, ហេតុនេះទើបអញខ្ញុំយកមករៀបរៀងទៀតជាសម្រាយស្ទោះ ដើម្បីឲ្យអស់សាធុជនបុរស-ស្ត្រីដែលមិនស្គាល់បាលី មើលយកសេចក្ដីបានដោយងាយ ទើបបញ្ជូនរឿងនេះមកទុកជាសម្បត្តិក្នុងព្រះរាជបណ្ណាល័យ ជាទីទស្សនាការបណ្ដាជនានុជន ដែលមកប្រជុំសន្និបាតមើលរឿងផ្សេងៗ ដើម្បីបម្រុងសតិបញ្ញាឲ្យជ្រះថ្លា ក្នុងព្រះពុទ្ធសាសនា តទៅ ។

សទ្ធារសោ ធាតុទាសកោ

# អនុត្តរិយសុត្ត

## អង្គុត្តរនិកាយ ឆក្កនិបាត

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

អញ្ញុំសូមនមស្ការ សម្តេចព្រះដ៏ទ្រង់ព្រះភាគដែលទ្រង់ឆ្ងាយចាកកិលេសហើយ ត្រាស់ជ្រាបនូវញេយ្យធម៌ទាំងពួងដោយព្រះអង្គឯង ៗ

សូមសម្តែងអនុត្តរិយសុត្ត សឹងមានពាក្យព្រះបាលីថា ឯវំមេ សុតំ ឯកំ សមយំ ភគវា ជាដើម អត្ថាធិប្បាយប្រែស្រាយជាសេចក្តីថា មានកាលសម័យថ្ងៃ ១ សម្តេចព្រះបរមលោកនាថសាស្តា-ចារ្យទ្រង់គង់សម្រាន្តឥរិយាបថ ក្នុងព្រះជេតវនដ៏ជាអារាម អនាថបិណ្ឌិកគហបតីសាងថ្វាយទៀបព្រះនគរសាវត្ថី សម័យនោះសម្តេចព្រះបរមជិនស្រីទ្រង់មានព្រះពុទ្ធតម្រាស់ត្រាស់ប្រាប់ពួកភិក្ខុទាំងឡាយថា ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ កិច្ចគឺអនុត្តរិយ មាន ៦ ប្រការដែលគ្មានកិច្ចដទៃប្រពៃលើសជាកិច្ចអ្វីខ្វះនោះគឺ ៖

១– កិច្ចមើលឃើញអ្វីដែលជាប្រពៃក្រៃលែង មើលវត្ថុផងទាំងពួង

២– ស្តាប់អ្វីដែលជាប្រពៃក្រៃលែង សម្លេងផងទាំងពួង,

៣– បានរបស់ដែលជាប្រពៃក្រៃលែង បានវត្ថុផងទាំងពួង,

៤- សិក្សាអ្វីដែលជាប្រពៃក្រៃលែង ផ្លូវសិក្សាទាំងពួង,

៥- បម្រើអ្វីដែលជាប្រពៃក្រៃលែង ឬបុគ្គលផងទាំងពួង,

៦- សេចក្តីរឭកនឹកដល់អ្វីដែលជាប្រពៃក្រៃលែង រឭកដល់វត្ថុទាំងពួង,

កាលសម្តេចព្រះពុទ្ធអង្គទ្រង់មានព្រះតម្រាស់ ដោយឧទ្ទេសដូច្នេះហើយ ទើបទ្រង់សម្តែងឲ្យច្បាស់ត្រចះត្រង់ វិសជ្ជនា ជាវិត្ថារ ពិស្តារជាដូច្នេះ ៖

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាក្នុងលោកនេះ បានទស្សនាមើលឃើញវត្ថុទាំងពួង គឺដំរីកែវ សេះកែវ ដួងកែវមណី នូវវត្ថុដ៏ឧត្តមវិសេសខ្ពស់ ដែលជាចម្លែក ប្លែកភ្នែក គួរត្រេកត្រអាលក្តី ឬមើលឃើញសមណព្រាហ្មណ៍ ដែលប្រព្រឹត្តិប្រតិបត្តិខុសក្តី ឬ ល្បែងទាំងពួងក្តី សូម្បីបុគ្គលបានមើលឃើញទាំងលំបាកនេះ ហើយមានសោមនស្សមនោរម្យ រីករាយសប្បាយចិត្តដែលបានមើលឃើញដូច្នេះ តថាគតមិនទុកថាបានមើលឃើញដោយប្រពៃ ចាត់ទុកថាបានមើលឃើញដោយទន់ទាប ជារបស់អ្នកស្រុកបុថុជ្ជន ញុំាងកិលេសឲ្យក្រាស់ មិនជារបស់ព្រះអរិយៈ មិនជាកិច្ចប្រកបនូវប្រយោជន៍ មិនប្រព្រឹត្តទៅនូវសេចក្តីរលត់នូវសេចក្តីរលត់នូវកិលេសមានតណ្ហាជាដើម មិនជាទីត្រាស់ដឹង មិនជាទីរលត់ ឲ្យប្រាសចាកកងទុក្ខ នូវព្រះនិព្វាន ។

បើបុគ្គលឯណាមានចិត្តចង់មើលចង់ឃើញ ដោយសេចក្តីជ្រះថ្លា

ស្នេហានឹងតថាគតនូវសាវ័កតថាគត បុគ្គលនោះឈ្មោះហៅថាមានកិច្ចបានឃើញដោយប្រពៃ ព្រោះហេតុដែលជ្រះថ្លាជឿជាក់ក្នុងគុណព្រះពុទ្ធនូវគុណព្រះអរិយសាវ័ក នោះនឹងនាំឲ្យមានសទ្ធាពុះពារកាប់កាត់ នូវកងកិលេសព្រាស់ចាកសន្ដាន មិនបានសោយសោកទុក្ខទោមនស្ស និងបានដល់នូវអរិយមគ្គ នូវព្រះនិព្វានជាទីបរមសុខសូន្យចាកទុក្ខ តថាគតចាត់ទុកជាកិច្ចបានឃើញដោយប្រពៃ គ្មានអ្វីប្រសើរលើសឈ្មោះហៅថាទស្សនានុត្តរិយ ជាកិច្ចទី១ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាក្នុងលោកនេះបានសវនាការស្ដាប់សព្ទសម្លេងផងទាំងពួងមាន សម្លេងភ្លេងនូវតូរ្យតន្ត្រីជាដើម, ទោះបើបុគ្គលនោះស្ដាប់សព្ទសម្លេងយ៉ាងឯកពិរោះចម្លែកប្លែក ត្រចៀកក្ដី ឬស្ដាប់ពាក្យសមណព្រាហ្មណ៍ឯណាដែលបដិបត្តិខុសពុំត្រឹមត្រូវក្ដី សូម្បីបុគ្គលនោះបានស្គាល់សព្ទសម្លេងទាំងអម្បាលនេះ ត្រេកត្រអាល សោមនស្សស្រស់រីករាយសប្បាយជាបំផុត តថាគតមិនចាត់ថាជាប្រពៃ ចាត់ទុកជាសេចក្ដីបានស្ដាប់ដោយទទាប ជារបស់អ្នកស្រុកបុថុជ្ជនដ៏ក្រាស់ទៅដោយកិលេស មិនជារបស់ព្រះអរិយៈ មិនជាកិច្ចដ៏ប្រកបដោយប្រយោជន៍ មិនជាទីប្រព្រឹត្តទៅឲ្យនឿយណាយ កាត់កំចាយកងកិលេសបានដល់នូវព្រះនិព្វានជាទីបរមសុខដ៏ប្រសើរ ។

តែថាបើបុគ្គលឯណាមានចិត្តជ្រះថ្លាប្រុងផ្ចង់តម្រង់ចិត្តស្ដាប់របស់ព្រះ

សទ្ធម្មគឺព្រះពុទ្ធវចនៈនូវសាវកសុភាសិត ជាពាក្យសិស្សព្រះសម្មាសម្ពុទ្ធ
តថាគតពាក់ទុកថាជាកិច្ច ដែលស្តាប់ដោយប្រពៃ ត្បិតបុគ្គលដែលមាន
សេចក្តីចង់ស្តាប់ទាប់ចិត្តតាំងត្រងសេព្រះសទ្ធម្មដោយចិត្ត ជឿក្នុងផ្លូវវត្ត
ប្រដិបត្តិ បុគ្គលនោះគង់កាប់កាត់នូវកងកិលេសប្រាសចាកសោយសោក
រង់ទុក្ខទោមនស្ស នឹងដល់នូវព្រះអរិយមគ្គ និងព្រះនិព្វានជាប្រាកដ បាន
ជាតថាគតពោលថាស្តាប់ព្រះធម៌នេះ ជាប្រពៃគ្មានអ្វីជាប្រសើរលើស
ឈ្មោះហៅថា សវនានុត្តរិយ ជាកិច្ចទី ៦ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាក្នុងលោកនេះបានលាភ
បានបុត្រក្តី ភរិយាក្តី វត្ថុក្តី ទោះបីវត្ថុនោះឥតវិញ្ញាណក្តី មានវិញ្ញាណក្តី
ល្អថ្លៃ តម្លៃវិសេសក្តី ឬមានលាភបានប្រសប់គប់នឹងសមណនូវព្រាហ្មណ៍
ដែលប្រព្រឹត្តបដិបត្តិ សុខក្តី សូម្បីបុគ្គលនោះ បានប្រកបដោយលាភ
ដូច្នេះជាមនុស្សជួរតាយសប្បាយចិត្តឥតទាស់ តថាគតក៏មិនយល់ថាជាប្រ
ពៃពាក់ទុកជាលាភយ៉ាងទន់ទាបជារបស់អ្នកស្រុកបុថុជ្ជន មិនមែនជាលាភ
ព្រះអរិយៈ មិនមែនជាប្រយោជន៍ ដើម្បីនូវសេចក្តីនឿយណាយប្រាសចាក
កិលេសក្នុងសន្តានឲ្យបានដល់នូវព្រះនិព្វាន ថាបើបុគ្គលឯណាមានលាភ
មានភ័ព្វ បានគប់គព្វប្រសព្វនឹងសម្តេច ព្រះបរមសាស្តាចារ្យ ឬសាវកអង្គ
ឯណា ហើយមានចិត្តជ្រះថ្លាជឿក្នុងផ្លូវសមាបដិបត្តិ កម្ចាត់កងកិលេស
គ្មានសេសសល់ប្រាសចាកកងទុក្ខទោមនស្ស សោយសោកបុគ្គល

នោះចំពោះថាទីដ៏បានអរិយមគ្គនូវព្រះនិព្វានជាប្រាកដ តថាគតចាត់ទុកជាប្រពៃគ្មានលាភអ្វីប្រសើរលើសឈ្មោះហៅថា លាភានុត្តរិយ ជាកិច្ចទី ៣ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយបុគ្គលឯណាក្នុងលោកនេះបានសិក្សានូវសិល្បសាស្ត្រគឺសិក្សាវិជ្ជាដំរី សិក្សាវិជ្ជាសេះ សិក្សាវិជ្ជាធ្នូរថ សិក្សាវិជ្ជាខាងបាញ់ សិក្សាវិជ្ជាហាត់រៀនអាវុធទាំងពួង ឬមានគេម្រិះពេះដឹងសព្វសារពើក្ដី ឬបានសិក្សាធម៌ក្នុងលទ្ធិសមណព្រាហ្មណ៍ ដែលបដិបត្តិសេចក្ដីសុខ សូម្បីបុគ្គលនោះ បានលាភយសខ្ពស់មាំមួន ដោយហេតុដែលបានពីព្រោះវិជ្ជាផ្សេងៗនោះក្ដី តថាគតមិនទុកជាប្រពៃ ត្បិតឃើញថាជាចំណេះទន់ទាប ជាចំណេះរបស់អ្នកស្រុកបុថុជ្ជនគ្រាស់ដោយកិលេសមិនមែនជាចំណេះវិជ្ជារបស់ព្រះអរិយៈ មិនមែនជាកិច្ចប្រកបដោយប្រយោជន៍មិនមែនជាទីកម្ចាត់ទុក្ខកំចាយកាមកិលេសឲ្យស្ដើង ។

បើបុគ្គលឯណាបានសិក្សានូវ សីលសិក្ខា ចិត្តសិក្ខា បញ្ញាសិក្ខា ឆ្លាតធ្ងះធ្ងុះយល់វិន័យញៀយធម៌ទាំងពួង អាចលលួងកាត់បំណង់កង់កិលេសឲ្យរលត់ តថាគតពោលថាជាកិច្ច សិក្សាដ៏ប្រពៃគ្មានអ្វីប្រសើរជាង រួចនូវសេចក្ដីទុក្ខទាល់កន្ទុល់ ទោមនស្សសោយសោក បានដល់ត្រូវព្រះអរិយមគ្គនូវព្រះនិព្វាន ឈ្មោះហៅថា សិក្ខានុត្តរិយ ជាកិច្ចទី ៤ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាក្នុងលោកនេះដែលបាន បម្រើបរមក្សត្រខត្តិយត្រកូលក្តី ឬបានបំរើសេនាបតី សេដ្ឋីគហបតី នូវផែនានុផែនធំតូចទាំងពួងក្តី ឬបានបម្រើសមណនូវព្រាហ្មណ៍ដែលប្រព្រឹត្ត ខុសពាស់ខឹងផ្លូវសមាបដិបត្តិក្តី សូម្បីបុគ្គលនោះបានលាភយសឧត្តមខ្ពស់ ព្រោះបម្រើ តថាគតក៏មិនសរសើរថាជាប្រពៃឃើញថាជាផ្លូវបម្រើដោយ ទន់ទាប ជារបស់អ្នកស្រុកបុថុជ្ជនដែលធ្ងន់ដោយកិលេស មិនជាផ្លូវ បដិបត្តិរបស់ព្រះអរិយៈ មិនជាទីរលត់ទុក្ខគោលគឺព្រះនិព្វាន ។

តែថាបើបុគ្គលឯណា មានចិត្តជ្រះថ្លាស្នេហាតថាគតនិងព្រះសាវក ដែលជាសិស្សានុសិស្សតថាគតឯណា ១ ហើយចូលមកបម្រើឱ្យប្រើជា ឧបដ្ឋាកពុំគិតលំបាកនឿយកាយចំខ្វល់ខ្វាយ ដើម្បីបដិបត្តិយកពាក្យ ប្រដៅកម្ចាត់បង់នូវឧបកិលេស កុំឱ្យសេសសល់បានដល់ព្រះអរិយមគ្គ នូវវិបត្តិផុតចាកទុក្ខទោមនស្សសោយសោក មានព្រះនិព្វានជាទីរលត់ ទុក្ខ តថាគតចាត់ថាជាកិច្ចបម្រើដ៏ប្រពៃ គ្មានអ្វីប្រសើរលើស ឈ្មោះថា ចារិចរិយានុត្តរិយ ជាកិច្ចទី ៤ ។

ភិក្ខវេ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯណាក្នុងលោកនេះមានចិត្តរឭក ដល់គុណទាំងពួងគឺ បុត្រក្តី ភរិយាក្តី ទោះយោបីតែនោះមានវិញ្ញាណក្តី ឥតវិញ្ញាណក្តីឬនឹករឭកដល់សមណៈនូវព្រាហ្មណ៍ ដែលប្រព្រឹត្តគិតខុស ពុំត្រង់ត្រូវជាផ្លូវ មិច្ឆាទិដ្ឋិក្តី សូម្បីបុគ្គលនោះនឹកដល់ហើយបាត់រំខាន

នាំមកនូវសេចក្តីក្សាន្តចិត្តឥតកង្វល់ នោះគេថាគេក៏មិនយល់ថាជាប្រពៃ ឃើញថាដែលទឹករព្វកដល់ផ្លូវច្នេះនេះជាធម្មតា អ្នកស្រុកបុថុជ្ជនប្រកបនូវកិលេសជាកិច្ចដ៏ទន់ទាប មិនជាកិច្ចរបស់ព្រះអរិយៈ មិនជាទីកម្ចាត់បង់នូវរាគៈ ទោសៈ មោហៈ បើបុគ្គលឯណាមានចិត្តជ្រះថ្លាជឿជាក់ក្នុងព្រះព្រះសម្មាសម្ពុទ្ធ ហើយមានមនោទឹករលឹកដល់ព្រះបរមពុទ្ធាទិគុណនូវព្រះសាវក ជាអ្នកប្រព្រឹត្តដោយប្រពៃអ្នកប្រព្រឹត្តដោយប្រពៃ ត្រឹមត្រូវទើបបាត់ជាផ្លូវសមាសតិដែលនាំបញ្ញាឲ្យមុតថ្លាអាចកាប់ផ្តាច់ពោគាទិកិលេសគ្មានសល់ បានដល់នូវព្រះអរិយមគ្គ មានព្រះនិព្វានជាបរិយោសានបាននូវបរមសុខ សេចក្តីទុក្ខទោមនស្សសោយសោកក៏រលត់ គេថាគេបាត់ទុកថាជាកិច្ចដ៏ប្រសើរ គ្មានសេចក្តីដែលរព្វកទឹកដល់ដ៏ប្រពៃលើស ឈ្មោះហៅថា អនុស្សតានុត្តរិយ ជាកិច្ចទី៦ ។

សម្តេចព្រះពិជិតមារជាម្ចាស់ ទ្រង់ត្រាស់ទេសនាព្រះសូត្រនេះចប់កាលណា ទើបទ្រង់សម្តែងនូវនិគមគាថាដូច្នោះ ត្រាស់ថាធម្មជាតិជាបណ្ឌិតទាំងឡាយរមែងទស្សនាការ ដែលត្រូវទស្សនាដ៏ប្រពៃដែលគ្មានធូលីប្រសើរលើស រមែងសវនាការស្តាប់សព្ទដ៏ប្រពៃដែលគ្មានអ្វីប្រសើរលើស រមែងស្វែងលាភដ៏ប្រពៃដែលគ្មានអ្វីប្រសើរលើស រមែងសិក្សានូវធម៌ដ៏ប្រពៃដែលគ្មានធម៌ដូចដទៃមកលាយឡំ រមែងនៅបម្រើបុគ្គលដ៏គួរសមបម្រើ ដែលគ្មានអ្វីប្រសើរលើស រមែងទឹករព្វកដល់បុគ្គលដ៏គួរ

ពួកដែលគ្មានអ្វីប្រសើរលើស រមែងរម្ងាប់ដោយសេចក្ដីស្ងប់ស្ងាត់ខំប្រួតកាត់ឲ្យដល់នូវអមតមហានិព្វាន ជាបណ្ឌិតរមែងមានគតិណាស់ក្នុងសេចក្ដីមិនប្រមាទ ជាអ្នកសម្រួមនូវឥន្ទ្រិយប្រកបដោយនូវសីល សមាធិ បញ្ញា បច្ឆេន្ទិ បានលុះនូវធម៌ជាទីរលត់ទុក្ខ ។

ចប់សេចក្ដីព្រះពុទ្ធដីកាអនុត្តរិយសុត្ត ដែលទ្រង់សម្ដែង ។

នឹងថ្លែងអធិប្បាយតាមក្រសែព្រះបរមពុទ្ធាភាស សូមពន្យល់ថា ជនៈ-ជាតិជនឯណាដែលមានចិត្តជ្រះថ្លាប្រាថ្នាឲ្យដល់នូវនិព្វាន ហើយប្រព្រឹត្តខ្លួនឲ្យមានជាឧបនិស្ស័យ លុះតែប្រកបដោយអនុត្តរិយ ទាំង ៦ ប្រការ ហើយអាចកាប់ផ្ដាច់នូវកិលេស គ្មានសេសសល់ ទើបបានដល់នូវព្រះនិព្វាន តែថាបើមានសេចក្ដីប្រមាទមិនខំសង្កត់លះឲ្យជ្រះ នូវកងកិលេស ប្រហែលជាចាំចាស់សិនបុំគិតធ្វើបន្ទុំ បុគ្គលដែលគ្មានអារម្មណ៍ដូច្នេះ ឈ្មោះហៅថាប្រមាទ ត្បិតកិលេសគឺរាគៈ ទោសៈ មោហៈ នេះដែលនឹងបានស្គាល់ស្រាលស្ដើង ក៏ចំពោះតែបុគ្គលដែលមានបតិសម្បជញ្ញៈ មានវិរិយៈគឺព្យាយាមបន្ទោបង់មិនបង្អង់ថាថ្ងៃណា បុគ្គលដែលមានឧស្សាហ៍ដូច្នេះ ឈ្មោះហៅថាមានសេចក្ដីមិនប្រមាទ ឯបុគ្គលដែលបានដល់នូវព្រះនិព្វានជាទីបរមសុខដ៏ប្រសើរនោះ ចំពោះមានតែបុគ្គល ៣ ជំពូក គឺសម្ដេចព្រះសម្មាសម្ពុទ្ធ ១ ព្រះបច្ចេកពុទ្ធ ១ ព្រះអរិយសាវកព្រះពុទ្ធ ១ លោកទាំងអម្បាលនេះសុទ្ធតែធ្លាប់បាន គឺព្យាយាមកោសរូសនូវកិលេស

គឺរាគៈ ទោសៈ មោហៈ ជាអនេកជាតិ ទើបបានសម្រេចមគ្គផល បានដល់នូវព្រះនិព្វាន ទឹងបានធ្វើតែម្តងបានក៏ទេ ហេតុនេះគួរតែពួកពុទ្ធសាសនិកជន ដែលជឿជាក់ក្នុងព្រះបវរពុទ្ធសាសនា ហើយមានប្រាថ្នាឲ្យរួចចាកទុក្ខទាំងពួង គួរខំធ្វើសីល សមាធិ បញ្ញាឲ្យហ្មត់ចត់ ទើបបានរលត់ផុតចាកទុក្ខ បើជាពុំអាចធ្វើខ្លួនឲ្យមានឧបនិស្ស័យជាអរិយបុគ្គល រឺសេចក្តីទុក្ខទល់តាមខស្សឧបទ្វន្តកាយ រមែងមានដល់កាយ មិនបេះផុតបានជាស្តេចព្រះសុគតទ្រង់ត្រាស់ថា បើនរជាតជនឯណាបដិបត្តិតាមពុទ្ធសាសនារាទ ពុំលំអៀងបុគ្គលនោះ ជាទៀងទឹងបានដល់បរមសុខ គឺព្រះនិព្វានដ៏មហាប្រសើរ ពណ៌នាមកជាសង្ខិតកថា ដោយសង្ខេបតែប៉ុណ្ណេះ ។

# រតនត្រយបូជា

## ព្រះគ្រូវិមលបញ្ញា អ៊ុម-ស៊ូរ

អាចារ្យព្រះរាជបណ្ណាល័យកម្ពុជា បានរៀបរៀង

## រតនត្រយបូជា

*រឿងបូជាសក្ការៈដល់ព្រះរតនត្រ័យ និងថ្វាយទេយ្យទានផ្សេង ៗ*

### ថ្វាយសក្ការៈដល់ព្រះពុទ្ធជាម្ចាស់ថា

ឥមិនា សក្ការេន ពុទ្ធំ អភិបូជយាមិ

ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះពុទ្ធជាម្ចាស់ ដោយគ្រឿងសក្ការៈមានប្រមាណប៉ុណ្ណេះ ។

### ថ្វាយសក្ការៈដល់ព្រះធម៌ជាម្ចាស់ថា

ឥមិនា សក្ការេន ធម្មំ អភិបូជយាមិ

ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះធម៌ជាម្ចាស់ ដោយគ្រឿងសក្ការៈមានប្រមាណប៉ុណ្ណេះ ។

### ថ្វាយសក្ការៈដល់ព្រះសង្ឃជាម្ចាស់ថា

ឥមិនា សក្ការេន សង្ឃំ អភិបូជយាមិ

ខ្ញុំព្រះករុណា សូមបូជាចំពោះនូវព្រះសង្ឃជាម្ចាស់ ដោយគ្រឿងសក្ការៈមានប្រមាណប៉ុណ្ណេះ ។

# សម្ដែងអំពីភត្ត ១៤ ប្រការ

បើឧបាសកឧបាសិកា មានបសាទសទ្ធា គឺសេចក្ដីជ្រះថ្លាកើតឡើងក្នុងសន្ដាន មានប្រាថ្នា នឹង ថ្វាយនូវភត្តទាំង ១៤ ថ្វាយភត្តប្រការឯណាមួយ ក៏បាន តាមប្រាថ្នា ។

ឯភត្តទាំង ១៤ នោះគឺ ៖

១-សង្ឃភត្ត ថ្វាយនូវភត្តដល់សង្ឃទាំងពួង,

២ ឧទ្ទេសភត្ត ថ្វាយនូវភត្តដល់ភិក្ខុ ១ អង្គ ឬ ២ អង្គ ឬ ៣ អង្គ ជាដើម តាមពាក្យដែលសង្ឃ សម្ដែងឲ្យ,

៣-និមន្តនភត្ត ថ្វាយនូវភត្តដល់ភិក្ខុ ដែលខ្លួននិមន្តមកហើយប្រគេន,

៤-សលាកភត្ត ថ្វាយនូវភត្តដល់ភិក្ខុទាំងឡាយ ដែលខ្លួនសរសេរឈ្មោះក្នុងស្លាកហើយចាប់,

៥-បក្ខិកភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃក្នុងសុក្កបក្ស គឺចំណែកខាងខ្នើត ឬកាឡបក្ស គឺចំណែកខាងរនោច តែក្នុង ១ បក្ស ប្រគេនតែ ១ ថ្ងៃ មិនមានកំណត់ថ្ងៃណា,

៦ ឧបោសថិកភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃ ក្នុងថ្ងៃឧបោសថកាល,

៧- ទាដិបទិកាភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃក្នុងថ្ងៃ១កើតឬ១រោច,

៨- អាគន្តុកាភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃទើបមកដល់,

៩- គមិកាភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃ ដែលមានដំណើរ ទំង ទៅកាន់ទីណាមួយ,

១០- គិលានភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃដែលមានជំងឺ ។

១១- គិលានុបដ្ឋាកភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃ ជាអ្នករក្សាជំងឺ,

១២- និច្ចភត្ត ថ្វាយនូវភត្តជានិច្ចដល់ភិក្ខុសង្ឃ,

១៣- កុដិកាភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃនៅទីលំនៅ មានកុដិជាដើម (ភត្តនេះហៅបានតាមឈ្មោះទីកន្លែងដែលសង្ឃនៅ)

១៤- វារកាភត្ត ថ្វាយនូវភត្តដល់ភិក្ខុសង្ឃ ដោយតាក់ជាវេន ។

ឯភត្តទាំង ១៤ ប្រការនេះ បើគេយកប្រាថ្នានឹងថ្វាយភត្តឯណាមួយ ឲ្យដាក់ឈ្មោះភត្តនោះ ត្រង់បាលីដែលវង់ក្រចកយ៉ាងនេះ ( ) ទុកនោះចុះ ។

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស (បីចប់) ។

អយំ ភោ ភន្តេ បិណ្ឌបាតោ ធម្មិកោ ធម្មលទ្ធោ ធម្មេន ឧប្បាទិតោ មាតាបិតុអាទិកេ គុណវន្តេ ឧទ្ទិស្ស (ឥត្ថនាមំ) សបរិក្ខារំ ពុទ្ធប្បមុខស្ស សំឃស្ស ទេម តេ គុណវន្តានយោ (ឥត្ថនាមំ) អត្តនោ សន្តកំ វិយ មញ្ញមានា អនុមោទន្តុ អនុមោទិត្វាន យថិច្ឆិត-សម្បត្តិយា សមិជ្ឈន្តុ សព្វទុក្ខា បមុញ្ចន្តុ ឥមិនានិស្ស-ន្ទេន ទុតិយម្បិ, តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ រីចង្ហាន់បិណ្ឌបាត នៃយើងខ្ញុំទាំងឡាយនេះ ប្រកបដោយធម៌ បានមកដោយធម៌ កើតឡើងដោយធម៌ យើងខ្ញុំទាំងឡាយ សូមឧទ្ទិសចំពោះដល់លោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើម ហើយយើងខ្ញុំទាំងឡាយ (វេរនូវកត្តមានប្រការនេះជាឈ្មោះ) ព្រមទាំងបរិក្ខារដល់ ព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន សូមលោកអ្នកដ៏មានគុណទាំងឡាយ មានមាតានិងបិតាជាដើមនោះ ចូរសម្គាល់ (នូវកត្តមានប្រការនេះជាឈ្មោះ) ថាដូចជារបស់នៃខ្លួន ហើយចូរអនុមោទនាយកចុះ លុះអនុមោទនារួចហើយ ចូរឲ្យរួចរដោះចាកទុក្ខទាំងពួង ឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ ៣ ប្រការ គឺសម្បត្តិមនុស្ស ១, សម្បត្តិទេវតា ១, សម្បត្តិព្រះនិព្វាន ១

ដោយសមគួរតាមសេចក្ដីប្រាថ្នា របស់លោកអ្នកដ៏មានគុណទាំងឡាយនោះចុះ ដោយអំណាចផលានិសង្ស ដែលហូរជូនមកមិនដាច់នេះហោង ៗ

អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ៗ

(ត្រង់បទថា ឥត្ថន្នាមំ នោះត្រូវបញ្ចូលឈ្មោះកត្តតាមប្រាថ្នា) ៗ

## បើថ្វាយចតុបច្ច័យជាសង្ឃទានថាដូច្នេះ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធាគេត្វា សំឃស្ស ទេម សាធុ ភន្តេ សំឃោ ឥមេ ចត្តារោ បច្ចយេ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ, តតិយម្បិ ៗ

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកដំកល់ទុកក្នុងទីនេះ ហើយថ្វាយដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃប្ដូរទទួលយក នូវបច្ច័យទាំងឡាយ ៤ នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ៗ

អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ៗ

## ថ្វាយចតុបច្ច័យដល់ភិក្ខុមួយរូបថាដូច្នេះ

មយំ ភន្តេ ឥមេ ចត្តារោ បច្ចយេ ឥធាគេត្វា អាយស្មតោ ទេម សាធុ ភន្តេ អាយស្មា ឥមេ បច្ចយេ

បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ទុតិយម្បិ តតិយម្បិ ។

*ប្រែថា បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ បាននាំនូវបច្ច័យទាំងឡាយ ៤ នេះ មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះករុណាម្ចាស់ដ៏មានអាយុ, បពិត្រព្រះករុណាដ៏ចម្រើន សូមព្រះករុណាទទួលយកនូវបច្ច័យទាំងឡាយនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។*

*អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ។*

## ថ្វាយកឋិនទានដល់ព្រះសង្ឃថាដូច្នេះ

ឥមំ ទុស្សំ កឋិនចីវរំ សំឃស្ស ទេម ទុតិយម្បិ តតិយម្បិ ។

*ប្រែថា បពិត្រព្រះអង្គសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយសូមថ្វាយនូវសំពត់នេះ ជាសំពត់ដើម្បីកឋិនចីវរ ដល់ព្រះសង្ឃជាម្ចាស់ ។*

*អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ។*

## ថ្វាយគ្រឿងបរិក្ខារជាបរិវារកឋិនថាដូច្នេះ

យេ ជម្ហាកំ កឋិនំ កហិតំ កឋិនានិសំសានិ នាសេស្សុ ទេម ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ កឋិនទៃយើងខ្ញុំទាំងឡាយ គឺលោកម្ចាស់អង្គណា បានទទួលកាន់យកហើយ យើងខ្ញុំទាំងឡាយ សូមថ្វាយនូវគ្រឿងបរិក្ខារ ជាបរិវារនៃកឋិនទាំងឡាយ ដល់លោកម្ចាស់អង្គនោះឯង ។

អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ។

សំពត់ ៧ ប្រការដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកឲ្យ ជាសំពត់សមណបរិក្ខារនោះ គឺសំពត់ត្រ័យចីវរ ១ សំពត់សម្រាប់ងូតទឹកភ្លៀង ១ សំពត់សម្រាប់ទ្រាប់អង្គុយ ១ សំពត់សម្រាប់ក្រាលជាកម្រាល ១ សំពត់សម្រាប់គ្របបូស, គ្របដំបៅ ១ សំពត់សម្រាប់ជូតមុខ គឺកន្សែង ១ សំពត់តូច ឬ ធំជាងប្រមាណហៅថា សំពត់បរិក្ខារចោឡៈ ១ បញ្ចូលសំពត់សម្រាប់ត្រងទឹក ១ សំពត់បំណាំវស្សា ១ និងសំពត់អច្ចេកចីវរ ១ ថែមទៀតជា ១០ ។

សំពត់ទាំង ១០ ប្រការនេះ បើទាយកប្រាថ្នា នឹងថ្វាយសំពត់ណាមួយដល់ព្រះសង្ឃ តែសំពត់នោះមានតែ ១ ត្រៃ ឬ ១ ផ្ទត់ ត្រូវឲ្យយកឈ្មោះសំពត់នោះជាបាលី ឯកវចនៈ មកដាក់បញ្ចូលនេះ ដូចមានសំណៅទុកខាងមុខនេះ ទាំង ១០ ប្រការ គឺ :

១- ឥមំ តិចីវរំ នូវត្រៃចីវរនេះ ។

២- ឥមំ វស្សិកសាដិកំ នូវសំពត់សម្រាប់ងូតទឹកភ្លៀងនេះ,

៣- ឥមំ និសីទនំ នូវសំពត់សម្រាប់ក្រាលអង្គុយនេះ,

៤- ឥមំ បច្ចត្ថរណំ នូវសំពត់សម្រាប់ក្រាលនេះ,

៥- ឥមំ កណ្ឌុបដិច្ឆាទិំ នូវសំពត់សម្រាប់គ្របបូស, គ្រប ដំបៅនេះ,

៦- ឥមំ មុខបុញ្ឆនចោឡំ នូវសំពត់សម្រាប់ជូតមុខតឹកខ្សែ នេះ,

៧. ឥមំ បរិក្ខារចោឡំ នូវសំពត់តូច ឬ ធំជាប្រមាណជា បរិក្ខារនេះ,

៨- ឥមំ បរិស្សាវនំ នូវសំពត់សម្រាប់ត្រងទឹកនេះ,

៩. ឥមំ វស្សិកសាដិកំ នូវសំពត់បំណាំវស្សានេះ,

១០- ឥមំ អច្ចេកចីវរំ នូវសំពត់អច្ចេកចីវរនេះ, ។

សំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរថ្វាយសំពត់ណាមួយ ឲ្យយកឈ្មោះសំពត់ដែលបានសំដៅទុកនោះ មកដាក់ក្នុងបាលីដែល សម្រាប់សូត្រវេរ ត្រង់កន្លែងដែលមានវង់ក្រចកទុកនៅនោះស្រាប់ ។.

មយំ ភន្តេ ឥមំ (តិចីវរំ) ឥធាគតា សំឃស្ស ទេម សាធុ ភន្តេ សំឃោ ឥមំ (តិចីវរំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពួនសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាន នាំមកនូវ (ត្រ័យចីវរ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើនអើយ សូមព្រះសង្ឃចូរទទួលយកនូវ (ត្រ័យចីវរ) នេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈ ២ ដងផង, អស់វារៈ ៣ ដងផង ។

សំពត់ទាំង ១០ ប្រការនេះ បើប្រាថ្នានឹងថ្វាយសំពត់ណាមួយដល់ព្រះសង្ឃ តែសំពត់នោះមានច្រើនត្រ័យ ឬច្រើនផ្ទត់ ត្រូវឲ្យឈ្មោះសំពត់នោះជាបាលី ពហុវចនៈ មកដាក់បញ្ចូលវេរ ដូចមានសំណៅទុកនៅខាងក្រោមនេះស្រាប់ ។

១. ឥមានិ តិចីវរានិ នូវសំពត់ត្រ័យចីវរទាំងឡាយនេះ,

២ ឥមា វស្សិកសាដិកាយោ នូវសំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ,

៣ ឥមានិ និសីទនានិ នូវសំពត់សម្រាប់ក្រាល់អង្គុយទាំងឡាយនេះ,

៤. ឥមានិ បច្ចត្ថរណានិ នូវសំពត់កម្រាលទាំងឡាយនេះ,

៥. ឥមានិ កណ្ឌុបដិច្ឆាទីនិ នូវសំពត់សម្រាប់គ្របបូសគ្របដំបៅទាំងឡាយនេះ,

៦-ឥមានិ មុខបុញ្ឆនចោឡានិ នូវសំពត់សម្រាប់ជូតមុខ ទាំងឡាយនេះ,

៧-ឥមានិ បរិក្ខារចោឡានិ នូវសំពត់បរិក្ខារទាំងឡាយនេះ,

៨-ឥមានិ បរិស្សាវនានិ នូវសំពត់សម្រាប់ត្រងទឹកទាំងឡាយ នេះ ។

៩-ឥមា វស្សាកសិកាយោ នូវសំពត់ចំណាំវស្សាទាំងឡាយ នេះ ។

១០-ឥមានិ អច្ចេកចីវរានិ នូវសំពត់អច្ចេកចីវរទាំងឡាយ នេះ,

ឯសំពត់ទាំង ១០ ប្រការនេះ បើត្រូវការនឹងវេរសំពត់ណាមួយឲ្យយក ឈ្មោះសំពត់នោះដាក់ក្នុងបាលី សម្រាប់សូត្រវេរខាងមុខនោះចុះ ត្រង់ កន្លែងដែលមានវង់ក្រចកនោះស្រាប់ ។

## ថ្វាយសំពត់ងូតទឹកភ្លៀងថា

មយំ ភន្តេ (ឥមា វស្សិកសាដិកាយោ) ឥធានេត្វា សំឃស្ស ទេម សាធុ ភន្តេ សំឃោ (ឥមា វស្សិកសាដិ. កា.យោ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ

បាននាំមកនូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ) មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះសង្ឃ បពិត្រព្រះសង្ឃដ៏ចម្រើន សូមព្រះសង្ឃចូរទទួលយក នូវ (សំពត់សម្រាប់ងូតទឹកភ្លៀងទាំងឡាយនេះ) ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង, អស់វារៈបីដងផង ។

## ថ្វាយសង្ឃទានបិ

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សេង្ឃត្វា សំឃស្ស ទេម សាធុ ភន្តេ សំឃោ ឥមានិ ខាទនីយ-ភោជនីយានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពង់សង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែងនូវវត្ថុទាំងឡាយមានខាទនីយភោជនីយាហារ គឺបង្អែមនិងចម្អាបជាដើមនេះ ហើយបង្អោនមកថ្វាយដល់ព្រះសង្ឃ បពិត្រព្រះគម្ពង់សង្ឃដ៏ចម្រើន សូមព្រះសង្ឃចូរទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចម្អាបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយអស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង, អស់វារៈបីដងផង ។

## ថ្វាយគណទានថា

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សទ្ធា សីលវន្តានំ ទេម សាធុ ភន្តេ សីលវន្តោ ឥមានិ ខាទនីយភោជនីយានិ បដិគ្គណ្ហន្តុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

*ប្រែថា បពិត្រព្រះករុណាម្ចាស់ទាំងឡាយ ដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបានតាក់តែង នូវវត្ថុទាំងឡាយមានខាទនីយភោជនីយាហារគឺបង្អែម និង ចម្អាបជាដើមនេះ ហើយបង្អោនមកថ្វាយដល់លោកម្ចាស់អ្នកមានសីលទាំងឡាយ បពិត្រព្រះករុណាម្ចាស់ទាំងឡាយដ៏ចម្រើន សូមលោកម្ចាស់អ្នកមានសីលទាំងឡាយ ចូរទទួលយកនូវវត្ថុទាំងឡាយ មានបង្អែមនិងចម្អាបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។*

*អស់វារៈពីរដងផង អស់វារៈបី ដងផង*

## ថ្វាយបាដិបុគ្គលិកទានថា

មយំ ភន្តេ ឥមានិ ខាទនីយភោជនីយានិ សទ្ធា សីលវតោ ទេម សាធុ ភន្តេ សីលវា ឥមានិ ខាទនី-

យេភោជនីយាទីនិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាន តាក់តែងនូវវត្ថុទាំងឡាយ មានខាទនីយភោជនីយាហារ គឺបង្អែម និងចម្អាប ជាដើមនេះ ហើយបង្អោនចូលមកថ្វាយព្រះករុណាម្ចាស់ បពិត្រព្រះករុណាម្ចាស់ដ៏ចម្រើន សូមលោកអ្នកមានសីល ចូរទទួលយកនូវវត្ថុទាំងឡាយ មានបង្អែម និងចម្អាបជាដើមនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង, អស់វារៈបីដងផង ។

## ថ្វាយអង្ករបា

មយំ ភន្តេ ឥមានិ តណ្ឌុលានិ ឥធានេត្វា សំឃស្ស ទេម សាធុ ភន្តេ សំឃោ ឥមានិ តណ្ឌុលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាន នាំមកនូវអង្ករទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ ហើយសូមថ្វាយដល់ព្រះសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃចូរទទួលយក

នូវអង្ករទាំងឡាយនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់ការៈពីរដងផង, អស់ការៈបីដងផង ។

## ថ្វាយផ្លែឈើផ្សេងៗបាលី

មយំ ភន្តេ ឥមានិ នានាផលានិ ឥធានេត្វា សំឃស្ស ទេម សាធុ ភន្តេ សំឃោ ឥមានិ នានាផលានិ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាន នាំមកនូវផ្លែឈើផ្សេងៗទាំងឡាយនេះ មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះសង្ឃ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូមព្រះសង្ឃចូរទទួលយក នូវផ្លែឈើផ្សេងៗទាំងឡាយនេះ ដើម្បីសេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់ការៈពីរដងផង, អស់ការៈបីដងផង ។

## វេរគ្រឿងសេនាសនៈតទៅ

## បើថ្វាយរោងឧបោសថថា

មយំ ភន្តេ(ឥមំ ឧបោសថាគារំ)ការេត្វា ចាតុទ្ទិសស្ស ភិក្ខុសំឃស្ស ទេម សាធុ ភន្តេ ភិក្ខុសំឃោ ( ឥមំ ឧ- បោសថាគារំ ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

*ប្រែថា បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយបាន ចាត់ចែងធ្វើ នូវ ( រោងសម្រាប់ធ្វើនូវឧបោសថនេះ ) ហើយសូមថ្វាយដល់ ព្រះភិក្ខុសង្ឃដែលមកអំពីទិសទាំង ៤ បពិត្រព្រះគម្តែងសង្ឃដ៏ចម្រើន សូម ព្រះភិក្ខុសង្ឃចូរទទួលយកនូវ ( រោងសម្រាប់ធ្វើនូវឧបោសថនេះ ) ដើម្បី សេចក្តីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខគ្រប់ប្រការដល់ យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។*

*អស់វារៈពីរដងផង, អស់វារៈបីដងផង ។*

## បើថ្វាយសាលាថា

ឥមំ សាលំ *នូវសាលានេះ ។*

## ថ្វាយកប្បិយកុដិថា

ឥមំ កប្បិយកុដឹ *នូវកប្បិយកុដិនេះ ។*

## ថ្វាយកុដិតូចហា

ឥមំ កុដឹ នូវកុដិតូចនេះ ។

## ថ្វាយកុដិធំហា

ឥមំ វិហារំ នូវកុដិធំនេះ ។

## ថ្វាយបង្គន់ហា

ឥមំ វច្ចកុដឹ នូវបង្គន់នេះ ។

បើប្រាថ្នានឹងវេរសាលាក្ដី កប្បិយកុដិក្ដី កុដិដ៏តូចក្ដី កុដិដ៏ធំក្ដី បង្គន់ក្ដី ទាំង ៥ យ៉ាងនេះ នឹងថ្វាយរបស់ណាមួយឲ្យយករបស់នោះ ទាំងបាលី ទាំងសម្រាយ មកដាក់ត្រង់កន្លែងដែលវង់ក្រចក ក្នុងបាលីដែលវេរពេញ ឧទាសថនោះហើយសូត្រវេរទៅចុះ ។

## ថ្វាយគរុភណ្ឌហា

មយំ ភន្តេ ឥមំ គរុភណ្ឌំ ឥណាទេត្វា ភិក្ខុសំឃស្ស ជេម សាធុ ភន្តេ ភិក្ខុសំឃោ ឥមំ គរុភណ្ឌំ បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ពែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ

បាននាំមកនូវវត្ថុភ័ណ្ឌនេះ មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃចូរទទួលយកនូវវត្ថុភ័ណ្ឌនេះ ដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង, អស់វារៈបីដងផង ។

## វេរគ្រឿងភេសជ្ជៈតទៅ

## បើថ្វាយទឹកឃ្មុំថា

មយំ ភន្តេ (ឥមំ មធុំ) ឥណាទេត្វា ភិក្ខុសំឃស្ស ទេម សាធុ ភន្តេ ភិក្ខុសំឃោ (ឥមំ មធុំ) បដិគ្គណ្ហាតុ អម្ហាកំ ទីឃរត្តំ អត្ថាយ ហិតាយ សុខាយ ។ ទុតិយម្បិ តតិយម្បិ ។

ប្រែថា បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើនអើយ យើងខ្ញុំទាំងឡាយ បាននាំមកនូវ (ទឹកឃ្មុំ) នេះ មកតម្កល់ទុកក្នុងទីនេះ សូមថ្វាយដល់ព្រះភិក្ខុសង្ឃ បពិត្រព្រះគម្ដែងសង្ឃដ៏ចម្រើន សូមព្រះភិក្ខុសង្ឃចូរទទួលយកនូវ (ទឹកឃ្មុំ) នេះដើម្បីសេចក្ដីចម្រើន ដើម្បីជាប្រយោជន៍ ដើម្បីសេចក្ដីសុខគ្រប់ប្រការ ដល់យើងខ្ញុំទាំងឡាយ អស់កាលជាអង្វែងទៅហោង ។

អស់វារៈពីរដងផង អស់វារៈបីដងផង ។

## បើនឹងថ្វាយប្រេងថា

ឥមំ តេលំ នូវប្រេងនេះ ។

## បើថ្វាយទឹកអំពៅថា

ឥមំ ជាធិតំ នូវទឹកអំពៅនេះ ។

## បើថ្វាយទឹកត្នោតថា

ឥមំ តាលោទកំ នូវទឹកត្នោតនេះ ។

## បើថ្វាយថ្នាំរក្សារោគថា

ឥមំ គិលានភេសជ្ជំ នូវថ្នាំសម្រាប់រក្សានូវមនុស្សឈឺនេះ ។

បើប្រាថ្នានឹងវេរ ប្រេងក្តី ទឹកអំពៅក្តី ទឹកត្នោតក្តី ថ្នាំរក្សានូវជំងឺក្តី ទាំង ៣ នេះ របស់ណាមួយ ឲ្យយកឈ្មោះរបស់នោះ ទាំងបាលី ទាំងសម្រាយ មកដាក់ក្នុងបាលីដែលវេរទឹកឃ្មុំនោះ ត្រង់កន្លែងដែលវង់ក្រចកនោះ ហើយសូត្រវេរទៅចុះ ។

## វិធីដែលវេរចតុបច្ច័យទាំង៤ ប្រការចប់ប៉ុណ្ណោះ ។

## សេចក្ដីដែលអ្នកអង្គម្ចាស់ ចន្ទឆាយាចង្ស អធិបតីក្រុមសមាគម បណ្ដាសិស្សានុសិស្សសាលារដ្ឋបាលតុលាការខ្មែរ សូត្រជាភាសាបារាំងនៅវេលាបូជាសព អ្នកអង្គម្ចាស់ សិង្ហរ៉ា ក្រុមការ ជុំ-ម៉ៅ ធ្វើរាជការនៅ ព្រះរាជបណ្ណាល័យ ប្រែជាភាសាខ្មែរ

---

សូមក្រាបបង្គំទូលព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សូមជម្រាបលោក ឡឺរេស៊ីដង់ សុប៉េរីយើរ និងអស់លោក អស់អ្នកទាំងឡាយ ទាំងស្រី-ប្រុស ។

តាងនាមក្រុមសមាគមបណ្ដាសិស្សានុសិស្ស សាលារដ្ឋបាល-តុលា-ការខ្មែរ និងតាងនាមមិត្រភក្ដិទាំងអស់ ខ្ញុំទទួលកិច្ចមកថ្លែងសេចក្ដីនៅទីនេះ ចំពោះមុខសពអ្នកអង្គម្ចាស់សិង្ហរា គឺដោយមានទុក្ខធំណាស់ ដែលខ្ញុំភ្ជាប់សេចក្ដីស្ដាយរបស់ខ្ញុំជាទីបំផុត ទៅនឹងសេចក្ដីស្ដាយរបស់មិត្រទាំងប៉ុន្មាន ។

អ្នកអម្ចាស់ សិង្ហរានេះ ជាមនុស្សដែលគេចូលចិត្តរាល់គ្នា ព្រោះលោកស្រឡាញ់រាប់អានអ្នកតូចនិងអ្នកទាបថោក លោកមានសេចក្ដីប្រាថ្នាតែម្យ៉ាងគឺសម្រាលនូវទុក្ខវេទនារបស់អ្នកក្រខ្សត់ ហើយបានខំឈឺឆ្អាលជ្រោមជ្រែងការជំនួញរបស់ជាតិខ្មែរ តាមកម្លាំងលោកដែលធ្វើបាន ឯកិច្ច

វេលរបស់លោកតែម្យ៉ាងនោះ គឺធ្វើឲ្យក្រុងកម្ពុជាបានថ្កុំថ្កើនរុងរឿង ឲ្យបណ្ដារាស្ត្របានសេចក្ដីសុខសប្បាយមិនក្រខ្សត់ និងឲ្យបានសេចក្ដីចំរើនដល់ជាតិ ព្រះអម្ចាស់សិង្ហកានតួចស្ដើង សក្តិសមកងកាយណាស់ មានបែបសណ្ឋានសុខសាធ នឹងព្រះសពព្រះវរាជបិតា គឺព្រះអង្គម្ចាស់ សុទ្ធា-រង្សទីអគ្គមហាសេនាធិបតី ដែលបានធ្វើការដើប្រសើរតបគុណក្រុងកម្ពុជានិងក្រុងបារាំងសែស ព្រះអង្គម្ចាស់សិង្ហ មានកិរិយាសុភាពរាបសា កេះកាយនិងអ្នកខ្សត់ខ្សោយ ហើយព្រះហឫទ័យល្អបំផុត ពេញជាកិច្ចរបស់ក្រសត្រ ទ្រង់បានធ្វើឲ្យខេមរជាតិទាំងឡាយយល់ច្បាស់ អំពីប្រយោជន៍នៃសេចក្ដីប្រស្រ័យយ៉ាងមាំនឹងគ្នាទៅវិញទៅមក ហើយដោយអំណាចគំនិតទ្រង់ និងតម្រិះវិជ្ជារបស់លោកនោះ ទ្រង់បង្កើតបានជាសមាគមច្រើន ។

អ្នកអង្គម្ចាស់សិង្ហ ប្រសូតក្នុងសង្កាត់លេខ ៣ ក្រុងភ្នំពេញ នៅថ្ងៃអាទិត្យ ១១ រោចខែភទ្របទ ឆ្នាំចសំរឹទ្ធិស័ក ត្រូវនឹងថ្ងៃ ១១ ខែសេបតេម ឆ្នាំ ១៨៩៨ ជ.ព្រះរាជបុត្រាព្រះអង្គម្ចាស់ពជាវតី ឧកេត្តម សុទ្ធារង្សទីអគ្គមហាសេនាធិបតី និងអ្នកម្នាងសម្រេច កាលព្រះជន្មបាន៧ខែនោះ ព្រះបាទសម្ដេចព្រះ ឧកេត្តម ជាព្រះរាជអយ្យកោ និងព្រះម្នាងឃិបជាអយ្យកា យកទៅបីបាច់រក្សាក្នុងព្រះបរមរាជវាំងតរៀងមក ព្រះអយ្យ-កោ និង អយ្យការំលាយខន្ធទៅ ។

កាលនៅពីកុមារនោះព្រះអយ្យកោ ទ្រង់មេត្តាពន់ពេកណាស់ហើយ អ្នកនគរទាំងប៉ុន្មានដែលបានឃើញ ក៏ស្រឡាញ់គ្រប់គ្នា ។

ទ្រង់បានចូលសិក្សាក្នុងបឋមសាលាបារាំងសែស ហើយខំសង្វាត ស្វាធ្យាយ លុះដល់បានថ្នាក់ជាន់ខ្ពស់ ដល់មកក្នុងខែដេសេមឆ្នាំ ១៩១៦ ទ្រង់ចូលដេញប្រយោគ បានសញ្ញាបត្រ បឋមសិក្សាវិជ្ជាបារាំងខ្មែរហើយ បានសិក្សាតទៅទៀតក្នុងសាលាកូលេសស៊ីសុវត្ថិកំណត់ ២-៣ ឆ្នាំ ក៏ដេញ ប្រយោគបានសញ្ញាបត្រ ទុតិយសិក្សាវិជ្ជាបារាំងខ្មែរទៀត រួចពីនោះទ្រង់ មានប្រាថ្នាចង់ឲ្យបានស្គាល់ខាងភាសាបារាំងតទៅ ក៏បានសុំចូលសិក្សា ក្នុងសាលាកូលេស សាស្សឺលូឡូបា នៅក្រុងព្រៃនគរទៀត ហើយដល់មក ខែស៊ូយេត ឆ្នាំ១៩១៨ ទ្រង់ដេញប្រយោគបានសញ្ញាបត្រ ប្រឺវេអេឡេម៉ង់-ទែរថែមទៀត តពីនោះមកទ្រង់បានចូលធ្វើរាជការក្នុងក្រុមព្រះអាលក្ខណ៍ រួចពីនោះ រាជការបាត់ទៅធ្វើរាជការនៅប៊ុយរ៉ូ ទី ២ នាទីរាជការរេស៊ីដង់ ស៊ុបេរីយើរ និងនៅទីប៊ុយរ៉ូរាជការតំណាងរេស៊ីដង់ ស៊ុបេរីយើរ មកប្រប សេនាបតីក្រសួងយុត្តិធម៌ខ្មែរ ។

គ្រាក្រោយមក ដោយទ្រង់មានប្រាថ្នានឹងសិក្សាឧត្តមវិជ្ជាទៀតនោះ ទ្រង់បានប្រឡងចូលធ្វើជាសិស្សសាលារដ្ឋបាលតុលាការខ្មែរ ទ្រង់ប្រឡង ចូលជាប់លេខ១ បានសិក្សាកំណត់ ២ ឆ្នាំហើយដោយសតិបញ្ញានិងសេចក្ដី ព្យាយាមយ៉ាងមាំមោះ ទ្រង់បានប្រឡងចេញជាប់លេខ ១ ទៀត តពីនោះ

មកទ្រង់បានតាំងជាអនុមន្ត្រីប្រមុងរាជការក្នុងដំណែងរាជការខ្មែរ ហើយដាក់ឲ្យនៅក្រៅដំណែង ដើម្បីបំពេញមុខក្រសួងជាអធិបតីរងក្រុមព្រះអាលក្ខណ៍ និងជាមេដឹកនាំព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង ។

ក្រោយមកទៀតទ្រង់បានឡើងថ្នាក់ត ៗ មក ជាអនុមន្ត្រីទី ២ និងទី ១ នៅក្រសួងគ្រប់កន្លែងដែលទ្រង់បានធ្វើការមានសេចក្ដីស្រឡាញ់រាប់អានគ្រប់គ្នា ហើយមានសេចក្ដីសរសើរជាច្រើន ដោយទ្រង់មានតម្រិះប្រាជ្ញាធ្វើរាជការត្រឹមត្រូវល្អ ។

កាលពីក្នុងខែសេបតម ឆ្នាំ ១៩២៦ ដោយទ្រង់ធ្វើរាជការមកនឿយណាស់ ហើយដោយមានរោគធ្លាក់ពោះវៀនបាយនៅខាងក្រោមផងនោះ ទ្រង់ក៏អាពាធ ហើយបានសុំច្បាប់ឈប់ដោយមានសេចក្ដីសង្ឃឹមថានៅថ្ងៃមុខនឹងបានចូលទៅធ្វើរាជការវិញ ប៉ុន្តែឯរោគនោះចេះតែចម្រើនធ្ងន់ឡើងបន្តិចម្ដង ៗ លុះដល់ទ្រង់ សុំអនុញ្ញាតឈប់ធ្វើរាជការ សម្រាកព្រះកាយពេលកំណត់ ៥ ឆ្នាំ ហើយទ្រង់បានស្ដេចទៅយកខ្យល់អាកាសនៅមាត់សមុទ្រនាទី ១ ហៅថាព្រែកក្ដាត តាមសេចក្ដីដែលគ្រូពេទ្យបានទូន្មាន តែព្រះរោគនោះ ចេះតែថែមធ្ងន់ឡើងឥតអាក់ ធ្វើឲ្យព្រះកាយថយកម្លាំងដុនដាបជាខ្លាំង ។

ឯសមាគមរបស់យើងខ្ញុំរាល់គ្នា នេះជាការកើតឡើង ព្រោះអ្នកអង្គម្ចាស់សិង្ហ ទ្រង់បានផ្ដួចសេចក្ដីតាំងពីកាលទ្រង់នៅជាអ្នករៀនក្នុង

សាលារដ្ឋបាលតុលាការខ្មែរម្ល៉េះ ប៉ុន្តែក្នុងវេលានោះឥតមានអ្នកជួយជ្រោមជ្រែងឲ្យគ្រប់គ្រាន់បរិបូណ៌ ឯសេចក្តីដែលទ្រង់បានផ្គងនោះ មិនអាក់ខានទៅសោះឡើយ គឺតពីនោះមកបានតិច ទ្រង់បានជួបនិងមិត្រខ្លះ ហើយក៏ក្រជុំគ្នារៀបតែង សេចក្តីរៀបដំណែង របស់សមាគមយើងឡើង កើតបានជាសមាគម ១ រំពេច បំពេញសេចក្តីចំណង់ដល់អ្នកនាំបង្កើតនេះៗ

អ្នកអគ្គម្ចាស់សិង្ហ បានបង្កើត សមាគមក្រៅពីក្រុមនេះទៀត កាលពីឆ្នាំ ១៩២៥ ទ្រង់បានជ្រាបថាខេមរសមាគម ទើបនឹងតាំងបង្កើតឡើងជាដំបូងនោះ ទ្រង់ក៏បានញ៉ាំងក្រុមចូលហ៊ុន តាំងប៉ុន្មានឲ្យមានសេចក្តីចំប្រើនកុំរួញរា ហើយបានបញ្ចុះបញ្ចូល ដល់ជាតិក្រស័ត្រគ្រប់អគ្គនិងបណ្តាពស្ត្រ ដែលមានទ្រព្យសម្បត្តិច្រើនឲ្យចូលក្ដាប់ខ្លួនក្នុងការនេះ ប៉ុន្តែដោយអ្នកកាន់កាប់ការ តាំងប៉ុន្មានមិនប៉ិនប្រសប់ ក៏សមាគមនេះរលាយទៅ អ្នកអគ្គម្ចាស់សិង្ហ បានសង្គ្រោះយកគោនសមាគមនេះពីសេចក្តីអន្តរាយជាច្រើនដងណាស់ ។

សេចក្តីដែលមិនបានសម្រេចតាមប្រាថ្នាខាងលើនេះ នាំឲ្យអ្នកអគ្គ-ម្ចាស់សិង្ហគិតខុសព្រោះឃើញថាគំនិតដែលផ្តើម ឲ្យបានបម្រើផលាសម្បត្តិដល់ព្រះនគរដែលជាតិខ្មែរបានបង្កើតឡើងនោះស្ថិតស្រពោនសាបសូន្យទៅវិញ ហើយមិនមែនព្រោះតែរឿងប្រាក់កាសដែលទ្រង់បានចេញជួយដោយស្មោះ ពីព្រះរាជហឫទ័យនោះទេ ដែលនឹងនាំឲ្យអ្នកអគ្គម្ចាស់

សិង្ហកធ្វើសង្គ្រោះគឺពីព្រោះតែគំនិតយ៉ាងឧត្តម ១ ក្នុងការជួសជុលសេចក្តីខូចខាតរបស់នគរ ឲ្យបានចម្រើនឡើងវិញ ។

ទ្រង់មិនបានបោះបង់គំនិតដែលនេះឡើយ គឺនៅវេលាក្រោយដែលខេមរសមាគមរលាយទៅ នោះទ្រង់ព្រះតម្រិះថានឹងតាំងបង្កើតជាហិបប្រាក់ជំនួយរបស់ក្សត្រាធិការ ១ ដែលមានប្រាក់ដើមចំនួន ៧០.០០០ រៀល ។ ហើយដែលទ្រង់ចេញទាំងអស់ពៃ ១ ព្រះអង្គឯង តែសេចក្តីមរណៈមកនាំយកទៅដោយទាំងគំនិតដ៏ឧត្តម ដែលទ្រង់បានគិតទៅជាមួយផង ក្នុងវេលានេះនគរក្រុងកម្ពុជា ខាតកូនសម្លាញ់ ១ នាក់បង់ ។

កាលពីឆ្នាំ ១៩១៨ ទ្រង់បានរៀបអាពាហមង្គល និងអ្នកអង្គម្ចាស់ក្សត្រី ដារ៉េអារវង្ស៍ ជាព្រះរាជបុត្រីសម្តេចក្រុមព្រះ ព្រះ តែាវបញ្ញា-នុជីវង្ស អធិបតីក្រុមសង្ឃហ: ហើយបង្កើតបានព្រះរាជបុត្រ ៤ អង្គនៅតូច ៗ ណាស់ដែលទ្រង់ទុកនៅជាខាងក្រោយ ។

មិត្តទាំងអស់ក្នុងក្រុមសមាគមបណ្តាសិស្សានុសិស្ស សាលារដ្ឋបាលតុលាការខ្មែរ បានមកជួបជុំគ្នាក្នុងវេលានេះ ដើម្បីបង្ហាញខ្លួនសោយទុក្ខជាទីគោរព ចំពោះព្រះរាជវង្ស ទ្រង់ទាំងប៉ុន្មាន ហើយព្រមទាំងរៀបធ្វើបុណ្យឧទ្ទិសថ្វាយព្រះរាជកុសលក្នុងថ្ងៃស្អែកនេះ ដោយក្រុងជំនុំកាន់កាប់សមាគមជាអ្នកចាត់ការ ។

គាត់នាងមិត្តភក្តិទាំងអស់ និងគាត់នាងខ្ញុំសូមអោយអ្នកជាស្រេចស្រឡះហើយ ខ្ញុំសូមព្រះក្តីមេត្តាស៊ូប្រជុំបណ្តាអ្នកក្នុងបរិសទ្ធជាតិមុខ ៗ

# ធម៌ទេសនាអំពីព្រះនិព្វាន

## របស់លោក កំម៉ង់ផង់ វ្វៃរត៍ សម្ដែងនៅព្រះរាជបណ្ណាល័យ

## កាលពីថ្ងៃ ៩ យូរ៉ាំង ឆ្នាំ១៩២៧ ក្រុមការ ជុំ ម៉ៅ

## បានស្រង់យកគោលតំ ៗ ស្ម័គ្រក្នុងនិកាស

## ជាមុនដែលសម្ដែងជាភាសាបារាំង

---

សេចក្ដីស្រង់អំពីធម្មទេសនាលោកកុំម៉ង់ផង់ វ្វៃរត៍ កាលពីក្នុងខែ អាព្រីល ឆ្នាំ ១៩២៦ លោកកុំម៉ង់ផង់ វ្វៃរត៍ បានអញ្ជើញមកសម្ដែងធម្មទេសនាមួយ ក្នុងព្រះរាជបណ្ណាល័យអំពី អរិយសច្ច ទាំង ៤ ប្រការ ហើយនៅថ្ងៃ ៩ យូរ៉ាំង ឆ្នាំ ១៩២៧ នេះ លោកមកសម្ដែងទៀត អំពីព្រះនិព្វាន ។

ធម្មទេសនាលើកទី ២ នេះ បានសម្ដែងទាំងអំពីមាគ៌ាសីលនិងភាវនា ជាឧបាយនិស្ស័យឬជាផ្លូវទៅកាន់ព្រះនិព្វាន ដែលអ្នកកាន់ពុទ្ធសាសនា ទាំងសង្ឃនិងគ្រហស្ថ ផ្ចង់ចិត្តសំរេចយក ហើយភ្ជាប់សម្ដែងអំពីផ្លូវឥតប្រយោជន៍ ដែលនាំឲ្យរកព្រះនិព្វានមិនឃើញ គឺកិរិយាប្រព្រឹត្តផ្លូវភេក និងតឹងពេក ដែលហៅថា កាមសុខល្លិកានុយោគ និង អត្តកិលមថានុយោគ ព្រមទាំងសម្ដែងអំពី មជ្ឈិមបដិបទា ដែលជាផ្លូវនាំទៅកាន់ព្រះនិព្វាន ។

អធិប្បាយអំពីរូបឈាន ៤ អរូបឈាន ៤ ដែលហៅថាសមាបត្តិ ៨ ប្រការ និងឈានថ្នាក់ខ្ពស់បំផុតដែលផ្ទាល់នឹងព្រះនិព្វាន ហើយដែលហៅថា សញ្ញាវេទយិតនិរោធ មានឧទាហរណ៍ថា ព្រះអរហន្តទាំងឡាយ លោកបានដឹងច្បាស់នូវព្រះនិព្វាននោះណាស់ តែដែលឃើញច្បាស់នោះ គឺជាប្រាកដតែក្នុងចិត្តនឹងយកសេចក្តីដែលជាក់ច្បាស់នោះ មកស្រាយឲ្យបំផាកសាមនុស្សឃើញដូច្នេះដូច្នោះ មិនកើត ព្រោះគ្មានពាក្យនិងថាឲ្យបំ មានអ្នកប្រាជ្ញជាតិគីរបម្នាក់ឈ្មោះ មាក់មុល្លែរ ដែលបានសិក្សាគម្ពីរក្នុងពុទ្ធសាសនាដោយជ្រៅជ្រះជាងគេ សម្តែងថាព្រះនិព្វាននោះយើងបានដឹងថាមានដោយពិតណាស់ តែនឹងថាឲ្យបំជាយ៉ាងនេះ ឬយ៉ាងនោះ មិនកើត ម្យ៉ាងទៀតមានអ្នកប្រាជ្ញជាតិក្លង់ឈ្មោះ សង្សូកាព្រេ សម្តែងថា មនុស្សខ្វាក់ដែលមិនដែល ស្គាល់ពណ៌លឿង ឬខៀវ និងថាមនុស្សក្នុងភូមិនស្គាល់ពណ៌ ឬថាក្នុងលោកនេះឥតមានពណ៌ក៏ថាមិនបាន ។

បានសម្តែងអំពីន័យផ្សេង ៗ ដែលអធិប្បាយពន្យល់អំពីព្រះនិព្វាន ក្នុងគម្ពីរនានា បានគម្ពីរ សំយុត្តនិកាយ មជ្ឈិមនិកាយ មហាវគ្គ ធម្មបទ អភិធម្មកោស ជាដើម ហើយសរុបសេចក្តីទៅឃើញថា ព្រះនិព្វាននេះ មិនមែនជាសូន្យទទេឡើយ គឺនៅមានសល់គុណអ្វី ១ ដែលយើងនឹងថា ឲ្យបំពោះមិនបាន មានឧទាន ១

ពណ៌នាថា កាលនោះមានពុទ្ធបរិស័ទ១អង្គចូលនិព្វាន ហើយព្រះសម្មាសម្ពុទ្ធទ្រង់សម្តែងថា រូបខន្ធរបស់អ្នកនោះ ឆ្ងាយទៅហើយ វេទនាខន្ធក៏ស្ងប់ម្ងាប់ ឬស្ងួតទៅអស់ សញ្ញាខន្ធ ក៏រលត់ សង្ខារខន្ធក៏ទៀយណាយ អស់អំណាច មិនអាចតាក់តែងរូបនិងនាមតទៅទៀតបានឡើយ វិញ្ញាណខន្ធ ក៏ចូលទៅអាស្រ័យក្នុងទីជ្រក ។

គម្ពីរសំយុត្តនិកាយ មានសម្តែងអំពីគោធិកភិក្ខុចូលនិព្វាន ហើយព្រះពុទ្ធអង្គអធិប្បាយនឹងពុទ្ធបរិស័ទថា វិញ្ញាណរបស់គោធិក ដែលចូលនិព្វាននោះ ឥតមានសល់ជ្រកនៅទីណា ១ ឡើយ ហើយវិនិច្ឆ័យសេចក្តីទាំង ២ យ៉ាងនេះថា ឯសេចក្តីទី ១ ដែលថាវិញ្ញាណចូលអាស្រ័យក្នុងទីជ្រកទីឈប់នោះ យើងនឹងថាគ្មានវិញ្ញាណក៏ថាមិនបាន ឯសេចក្តីទី២ ដែលថាវិញ្ញាណឥតមានសល់ជ្រកនៅ ក្នុងទីណា ១ ឡើយ នោះយើងត្រូវយល់ថា ឥតមានសល់ជ្រកនៅក្នុងទីណា ១ ក្នុងលោកយើងនេះទេ ព្រោះព្រះនិព្វាន ជាលោកដទៃទៀត អំពីលោកយើង ។

មានបុច្ឆាថា ចុះហេតុអ្វីបានជាព្រះសម្មាសម្ពុទ្ធ មិនសម្តែងឲ្យច្បាស់ថាព្រះនិព្វាននោះជាអ្វី ត្រង់នេះឃើញមានសេចក្តី ដែលព្រះអង្គទ្រង់សម្តែងនឹងមាលុង្ក្យបុត្រ ថាព្រះនិព្វាននោះ ជាគុណជាតិល្អិតជ្រៅពេកណាស់ ហួសវិស័យអ្នកស្តាប់ត្រូវឲ្យគិតតែពីពាក្យសច្ចទាំង ៤ វិញ ព្រះសម្មាសម្ពុទ្ធសម្តែងក្នុងឋាន ១ ថា ព្រះនិព្វាននោះជាទីដែលគ្មានទឹក

ដី-ភ្លើង-ខ្យល់ មិនមែនជាវាលទទេស្អាត មិនមែនជាទីដែលគ្មានអ្វីសោះ មិនមែនជាមានវិញ្ញាណ មិនមែនជាឥតវិញ្ញាណ មិនមែនជាក្នុងលោកនេះ មិនមែនជាក្នុងលោកខាងនាយ មិនមែនជាយប់ និងមិនមែនជាថ្ងៃ ។

បើដូច្នេះតថាគតមិនហៅថាមក - មិនហៅថាទៅ - មិនហៅថានៅ - មិនហៅថាស្លាប់ - មិនហៅថាកើត ហៅថាគ្មានដើម - គ្មានទៅជាអ្វី គ្មានផុត គឺជាសេចក្តីរលត់ទុក្ខ ឥតត្រឡប់មកកើតវិញ ។

នៅវេលាដែលព្រះអរហន្ត លោកចេញអំពីឈានមកវិញនោះលោកបន្លឺឧទានថាដូច្នេះ ព្រះនិព្វានជាទីរលត់នូវសេចក្តីប្រាថ្នា, ជាទីសប្បាយ ជាទីសុខបំផុតរកអ្វីផ្ទឹមមិនបាន ប៉ុន្តែទំនងអធិប្បាយអំពីសេចក្តីសប្បាយ សេចក្តីសុខនោះ ថាដូច្នេះដូច្នោះមិនបាន ដូចបានពោលមកខាងដើម បើដូច្នេះតើយើងត្រូវវិនិច្ឆ័យសេចក្តីថា ព្រះនិព្វាននោះ ទទេសូន្យឥតមានអ្វីសោះឬអ្វី? ។

សេចក្តីដែលបញ្ជាក់នោះ បានញែកព្រះនិព្វានជា ២ ចំណែក ១ និព្វានធម្មតា ឬ សឧបាទិសេសនិព្វាន ដែលព្រះអរហន្តលោកបានដល់តាំងពីកាលរស់នៅ ១ ទៀតគឺបរិនិព្វាន ឬ អនុបាទិសេសនិព្វាន ដែលចាប់តាំងពីព្រះអរហន្តទម្លាយបញ្ចខន្ធទៅ ។

ឯព្រះនិព្វានធម្មតានោះ គឺជាកិរិយាដែលព្រះអរហន្តទាំងឡាយលោកលះបង់ចោលនូវសញ្ញា សេចក្តីពិតប្រាកដ សេចក្តីទៀងជានិច្ច

ឥតកើត ឥតស្លាប់ នៅវេលាដែលកំពុងធ្វើឈាន ឯចរិទិញ្ញានវិញនោះ គឺជាទីសុខទីទៀងជានិច្ច ឥតប្រែប្រួល ដែលមានតាំងនៅហើយ ដែលយើងនឹងថាជាអ្វីឲ្យចំមិនកើត ។

ធម៌ទេសនានេះ ថ្ងៃក្រោយនឹងមានបោះពុម្ពជាសេចក្ដីពិស្ដារ នៅវេលាដែលបានប្រែជាភាសាខ្មែរហើយស្រេច ។

# ពាក្យកាព្យបុរាណ

របស់លោកអ្នកឧកញ៉ា វង្សាសារពេជ្ញ ជុំ បានប្រែចេញពី បាលី ហើយនិពន្ធជាពាក្យឃ្លោង តាំងពីក្នុងរជ្ជកាលព្រះបាទសម្ដេច ព្រះ ហរិរក្សរាមា ព្រះ អង្គដួង ព្រះពុទ្ធវង្ស អ៊ុ តាំងបរិច្ឆេទ និង ព្រះគ្រូវិមលបញ្ញា អ៊ុម-សូរ អាចារ្យក្នុងព្រះរាជបណ្ណាល័យ បានយកមក ពិនិត្យផ្ទៀងផ្ទាត់ ឲ្យបានត្រឹមត្រូវឡើង

| | | |
|---|---|---|
| ចាណាកិចាត | ទាអ្នកទេហាទ | បិត្តពោរពោទបង់ |
| ពិឃាដម្រិតា | មញ្ជូនវេគ្គ | មនុស្សសត្វឲ្យបង់ |
| | ឲ្យបាត់ជន្មា | ។ |
| អ្នកនោះទឹងទៅ | រងបាបក្ដាត់ក្ដៅ | លំបាកនៅនា |
| សញ្ជីវនរក | រស់ក្នុងឈឺឆ្អូ | ទុរនទុក |
| | រូបរងយូរព្រៃ | ។ |
| យមបាលបោះ | ទៅក្នុងភ្លើងស្មោះ | ខ្ទុះឆេះក្បាលក្បែយ |
| ហើយរស់រូបរឹង | ក្ដីដឹងកិតក័យ | ជាវិលមកញ |
| | ផល់នាត់រណ្ដៅ | ។ |
| យមបាលចរ | ពោមចាក់ទឹងស្នូរ | មូលញ្ជូកដែកក្ដៅ |
| ចាក់ទឹងលំដែង | លើកសែកហោលទៅ | ក្នុងទីរណ្ដៅ |
| | ភ្លើងក្នុងកព្វន្ត | ។ |

កំណត់ជន្មា　នរកនោះហា　រយឆ្នាំប្រមាណ

គិតគណនាឆ្នាំ　ត្រូវប្រាំបួនលាន　មនុស្សនេះទើបបាន

មួយថ្ងៃនរក　។

លង់លុះរលោះ　ពីនរកនោះ　មកមិនដែលសុខ

កើតជាមច្ឆា　មានតាជ្រុកស្រុក　គេកាប់ហាប់លក់

ប្រាំរយជាតិជាក់　។

ទៀតទើបកើតជា　មនុស្សមានទោសា　គេបាញ់គេចាក់

គេដោតគេកាប់　សម្លាប់ឥតអាក់　ប្រាំរយជាតិជាក់

ពិតពុំសុះអង្គ　។

ហើយយកជាតិជា　មនុស្សមានរោគា　ដំបៅភកឃ្លង់

ជាមនុស្សគមគាក់　ក្ដៅក្ដាក់ខ្ទិនខ្ទន់　ក្រៃធ្ងន់

ក្ដារអប្រិយ　។

បើបានសក្តិបុណ្យ　ត្បិតផលជាតិមុន　បានហាក់មកក្ដី

តៀវកម្មកាត្ថា　ឲ្យអាយុខ្លី　ពុំយឺនដី

ជំរិតដល់ចាស់　។

ទោះទុក្ខព្រួសព្រើ　កាយកម្មក្របើ　ព្រោះបង់គ្រូខ្លាស់

ប្រឡាប់លែងលាប　ស្រែប្រួសពោរ　ដីធ្លីយេះបញ្ច្រាស់

ទន់ទន់យល់យល់　។

ខ្លាចបាបខ្លាសបាប ចៀសវាកផកប ជីវិតសត្វសល់
ពិតពុំពណនា ក្រោតម្កល់ ចិត្តចាំសីលផល
បាណាតិបាត ៗ

បានទៅកើតនា សួគ៌ចាតុម្មហា· រាជិកាជាតិ
ជាអគ្គទេវបុត្រ បរិសុទ្ធស្អាត ស្ថិតលើប្រាសាទ
ប្រាំពីរយោជន៍គត់ ៗ

ស្រីទេពកញ្ញា ប្រាំរយអគ្គា បម្រើបាទបត់
ចូលបន្ទំគាល់ រៀងរាល់ប្រាកដ ប្រកបកំណត់
កំណាន់សព្វថ្ងៃ ៗ

ប្រាំរយឆ្នាំគត់ ទើបទេពបុត្រ មកកើតនៅភ្ល
ត្រកូលក្សត្រិយ៍ក្សាន្ត សន្តានថ្លាថ្លៃ រូបពណ៌ល្អក្រៃ
មានលក្ខណាក្ដាត់ ៗ

មានកម្លាំងរឹងណែន មានចិត្តទោទន់ ប្រណីទុក្ខសត្វ
មានកូនមានចៅ ញាតិផៅពុំព្រាត់ ពុំប្រាសខ្លាយខ្លាត់
ជាសុខដល់ចាស់ ៗ

ពុំដែលក្សិណក្ស័យ ជីវិតប្រាល័យ ដោយគ្រឿងសហាស
បាខាវិការោគ អនេកច្រើនណាស់ ឥតទុក្ខទោសពាស់
ឥតព្យាធិ៍ពេលា ៗ

ឥតមានសត្រូវ　កំណាចក្អាតក្អូវ　បៀតបៀនបណ្ដា
អាយុយឺនយូរ　បរិបូណ៌ជន្មា　នេះផលបុណា
ពិបាកប្រមាន　ៗ

អធិដ្ឋានា　មនុស្សល្អប្រពា　គេគិតចង់បាន
បំបាត់បញ្ចោត　បំពោតបំពេន　បំភាអាងមាន
យសសក្ដិខ្ពស់ខំ　ៗ

លុះលៃងជាតិទៅ　ឧកេទាមហៅ　កាឡស្លូតអស់យម-
កូបាលចាប់ចង　ដាក់ផងដាល់ដំ　ឈើផ្សារភោគពុំ
ស្មុខសោយទុក្ខា　ៗ

ទើបយកបន្ទាត់　ដែកដុតមកផ្ទាត់　សុខសព្វកាយោ
ខ្ទុះយករណារ　មកអារអង្គារ　ពុះពីសិរសា
ទល់ទុក្ខទោទន　ៗ

ឈាមហូរសស្រាក់　ប្រែសកយ៍ផ្ទកអាក់　គិតភ័យតាំងកាន់
នៅនានរក　វេទុក្ខកំណាន់　កំណត់មួយពាន់
ឆ្នាំទើបរដោះ　ៗ

មួយពាន់ឆ្នាំត្រៃ-　ត្រឹមត្រើបមួយថ្ងៃ　ទាននរកនោះ
យូរពន់ប្រមាណ　លុះបានរួចស្មោះ　ពីនរកនោះ
មកជាប្រេតបាន　ៗ

កម្ពស់ត្នោតពៃ រូបអាក្រក់ក្រៃ រកស៊ីស៊ីគ្មាន

ស៊ីសឹងតែលាមក ជាទុក្ខអត់ឃ្លាន ប្រាំរយជាតិបាន

មកកើតជាមនុស្ស ៗ

កំសត់ពិបាក អត់ឃ្លានៈតោកយ៉ាក ទុគិតទុភិស

ដើរសូមទានស៊ី ឥតគេសប្បុរស ក្រិណខ្សត់របស់

ប្រាំរយជាតិទៀត ៗ

មានទ្រព្យតិចតួច ចោរចាំលបលួច បានបាត់បង់ទៀត

កើតជាខ្ញុំគេ ម្ចាស់ដេរវាយទៀត បាបត្បិតបៀនបៀត

ទ្រព្យអ្នកដទៃ ៗ

បើអ្នកឯណា មួយមានប្រាជ្ញា ដវែនរង់វៃ

រៀនរកវិជ្ជា ទានជាបច្ច័យ មគ្គផលអាស្រ័យ

សមានបរភោគ ៗ

រៀនដំនួញប្រាំ ប្រការចេះចាំ ចិត្តរេះអធ្យោគ

អធ្យាស្រ័យយល់ ទៅដល់បរលោក ខ្លាចកម្មទុក្ខសោក

ជិតដល់អាត្មា ៗ

អ្នកនោះមិនបាន ទៅកើតនៅស្ថាន សួគ៌ត្រៃត្រឹង្ស

មានទិពាបុរ បរិកញ្ញា មួយពាន់ចោមជា

បរិវារគន្ធតាល់ ៗ

ឋិតវិមានខ្ពស់ ប្រមាណឫទេស យោជន៍យល់ឆើតឆាយ
ត្រដែតត្រដួច បង្គួចរៀងកល់ សឹងមានពិព័ណ៌
ពិពិធរចនា ។

សោយសុខប្រមាណ មួយពាន់ឆ្នាំមាន ទើបយកជាតិជា
ត្រកូលក្សត្រិយ៍ក្សាន្ត មែនមានប្រាជ្ញា ធនធានសក្តា
ច្រើនពន់ពេកក្រៃ ។

ទើបយកជាតិជា ត្រកូលខែមហា សេដ្ឋីប្រពៃ
មានទ្រព្យរបស់ សក្តិយសថ្លាថ្លៃ ឥតអ្នកដទៃ
ណាទិតបៀតបាន ។

តោះតោះខ្ញុំញាំង សម្រេចបៀតបាំង លាយលោកធនធាន
ចិត្តបង់វិកវ ប្រមាទពុំបាន ហេតុនោះអ្នកមាន
ផលលោះលាភដែន ។

គាមេសុមិទ្ធា តោះអ្នកឯណា ចិត្តនោះរង្វង់
លួចកិរិយាគេ កកដងមាសក្រូង ស្រីផិតក្តីឯង
ស៊ីរ៉ាំរោលតក្តុត ។

អ្នកនោះទីងទៅ ដល់ទុក្ខនិព្វទៅ សំយាជនរក
តាំងប្រុសតាំងស្រី [illegible] រូបរងពាលទុក្ខ
ពារ៉ាបុរាណមហិមា ។

| | | |
|---|---|---|
| យមបាលបាន | ដាក់ដែកក្ដៅក្រាន | ឡើងដើមរកា |
| ដែកដាលជាភ្លើង | ខ្ពស់ឡើងកណ្ដាល | មួយយោជន៍បន្ទា |
| | ច្រើនប្រេះប្រាតប្រួន | ។ |
| ស្រីពានឡើងមុន | មុតខ្លួនខ្ទួន | ស្រែកយំលួង |
| ប្រុសឡើងតាមទៅ | មុត ដាក់ដើមទ្រូង | ចុះម្ដើមបេះដួង |
| | ឈាមហូរសស្រាក់ | ។ |
| មានក្អែកប្រវាល | ប៉ុនដំរី | ចឹកខាំក្ដោក់ |
| ជើងដែកប៉ារែក | គ្មានក្ដីគន្ធកធាក់ | ចឹកបោះចុះធ្លាក់ |
| | ខ្លួនដល់ដែកដាល | ។ |
| ឆ្មាឆេះជាភ្លើង | [illegible] | ក្រោងក្រាយន្ទាល |
| ឆេះខ្លួនក្រៀមក្រំ | [illegible] | បាបណ្ដាញដាល |
| | [illegible] | ។ |
| ស្លាប់មួយថ្ងៃពីរពាន់ | [illegible] | គិទិតអសៅ |
| អសារអះសាប | [illegible] | ពីរពាន់ឆ្នាំទៅ |
| | [illegible] | ។ |
| អាយុពីរពាន់ | [illegible] | យោមាស្មួគិសុខ |
| ទើបបានមួយថ្ងៃ | [illegible] | រដ្ឋចោសទុក្ខ |
| | [illegible] | ។ |

សត្វតិរច្ឆានធុក គេគៀរធ្វើទុក្ខ ទោសតាមវេរា
កាយកម្មអង្គឯង វេទ្ធន៍មោហា ប្រាំរយជាតិជា
ទុក្ខទៀងអប្រិយ ៗ

កើតជាខ្ទួចខ្ទួយ ប្រាំរយជាតិហើយ កំព្រាឥតប្ដី
ដោយទូរវៀរវី តាកពីបូរី បូរមជាតី
បាបជាទម្ងន់ ៗ

ទើបកើតជាប្រុស អាក្រក់ទូរយស មកមានប្រពន្ធ
ពោរចិត្តជាផិត ពុំគិតបាបបុណ្យ ហេតុពៀរពីមុន
បរទារកកម្មគេ ៗ

បើអ្នកណាមាន វិញ្ញាញយ្យញាណ ប្រុងប្រុងប្រុះប្រែ
ចិត្តចេះចាំចៀស រវៀសបានវៃរ វៀរបាកកាយ
សុមិច្ឆាចារ ៗ

អ្នកនោះទឹងទៅ សោយសម្បត្តិនៅ សុខសួគ៌យាវា
ស្ថិតលើប្រាសាទ ស្អាងស្អាតសោភា កម្ពស់គន្ធា
វេយេយោជន៍យល់យង់ ៗ

ភ្ញុំផ្ទុកចិញ្ចាប ចំពួនត្រូវជាប ត្រួចដោះព្រុំ
មានទេពអប្សរ ចរនារលំពង ពីរពាន់សំរួល
នោមនាយសុខ ៗ

អាយុពីរពាន់ ឆ្នាំទើបគ្រប់គ្រាន់ ហាកបរបៀត
យោនយកកំណើត មកកើតជាបុត្រ ក្សត្រិយ៍ថ្ងៃវិសុទ្ធ
វិសេសប្រសើរ ៗ
ប្រកបកិរិយា ត្រឹមត្រូវលក្ខណា គាប់គួរមៀងមើល
ជាស្រីគ្រប់លក្ខណ៍ ឯកអគ្គប្រសើរ ទោះដេកទោះដើរ
សើងជាសុខសល់ ៗ
កុសលាពាលា ទោះអ្នកឯណា កុំហកកាចកល
មានពាក្យរឹងរូស ប្រមូស្តកំហាល់ កំហឹងកៃកល
កៃកាចកំបូះគ- ៗ
បញ្ចុកបញ្ចោត បញ្ចៀវបំភាត បំពានវៀចវេរ
ពោលពាក្យកួតករ បង្អាស្រោលស្រែ ឲ្យបង់ទ្រព្យគេ
ឲ្យគេកើតទុក្ខ ៗ
អ្នកនេះខឹងទៅ ចល់ទុក្ខចង្រៅ កោពេនកេ
បានបួនពាន់ឆ្នាំ រងំបុក្ខំសុខ ព្រោះមាត់អាក្រក់
ពោលពាក្យមុសា ៗ
យមម្ចាលយក ដណ្ដាប់ដែកមក ដុតដកដីហ្ល
ឈាមហូរសស្រាក់ កន្ត្រាក់តក្អិត ទោលប៉ុះក្តួរម៉ា
រក្តាក់តក្អែ ៗ

ប្រាំពាន់ឆ្នាំណា សួគ៌តុសិតា ទើបបានមួយថ្ងៃ
កោរពនរក រងទុក្ខរងភ័យ យឺនយូរកម្រៃ
កម្ររដោះ ៗ

លុះរួចមកបាន កើតជាប្រែតប្រាណ អាសោចិសូទ្យសោះ
កម្មកើតអគ្គី ឆេះពីមាត់នោះ ស៊ីសឹងឈាមខ្ញុះ
ជាតិជាអាហារ ៗ

ទើបកើតជាមនុស្ស អាក្រក់ទុរយស មាត់វៀចឆៃបឆា
កើតជាមនុស្សល្ងង់ គង្វង់ឥតការ ឥតកេរ្ត៍អសារ
អាសោចិពីមាត់ ៗ

បើអ្នកឯណា វៀរពាក្យមុសា វាងវៀរគិតកាត់
កាន់សច្ចវាទី ស្រដីពាក្យសត្យ នឹងបានសម្បត្តិ
សួនសោយសុខា ៗ

ពិភពតុសិត អាយុយឺនក្តាត់ បួនពាន់ឆ្នា
មានទេពអប្សរ បវរធីតា បួនពាន់ជាតិជា
បរិវារសព្វថ្ងៃ ៗ

បិតលើប្រាសាទ ប្រសើរស្អាងស្អាត សឹងកែវប្រពៃ
ខ្ពស់ម្ភៃប្រាំយោជន៍ ស្រោងស្រោបត្រៃលែប សុខសប្បាយប្រៃ
ឥតឯឧបមា ៗ

បានបួនពាន់ឆ្នាំ　ទើបផលសោតចាំ　ចុះមកកើតនា
ត្រកូលក្សត្រិយ៍ក្សាន្ត　មែនមានប្រាជ្ញា　ទើបទៅកើតជា
អ្នកប្រាជ្ញបេះធម៌ ។
មែនមានពាក្យសត្យ　ពាក្យពិរោះក្តាត់　បេះចាំអស់អាថ៌
ចំណោទប្រស្នា　បញ្ហាសព្វសារ-　តើពុំទើសទាល់
ផល់ប៉ុនកេសី ។
ស្រុកមេរយា　វីមនុស្សផឹកស្រា　ភ្លេចភ្លាំងស្មារតី
ក្រសាលជាល្បែង　ពុំក្រែងពារី-　បាកបាបស្រដី
ពុំជឿធម្មា ។
ទឹងធ្លាក់ទៅនៅ　នរកជ្រៅលជ្រៅ　រូបរងវេទនា
ផល់ផាបនរក　ទល់ទុក្ខមហិមា　យឺនយូរគណនា
ប្រាំបីពាន់ឆ្នាំ ។
ហេតុចិត្តឆ្ងើង　ផឹកទឹកទង់ដែង　ក្តៅក្តាត់ជោកជាំ
លោករលុះ　ពន់ពុះដោយកម្ម　ប្រាំបីពាន់ឆ្នាំ
ខ្មាននរតី ។
ទើបបានមួយថ្ងៃ　នរកយូរក្រៃ　លន់លុះឡើងពី
បាបបានកើតជា　យក្សាត្រិយ៍　ជាមនុស្សអប្រិយ
សឹងឆ្កួតពុធ្យា ។

មានពាក្យអសុរស ពាក្យរឹងត្រគោះ លលើលលា
អ្នកផងតិះដៀល ជំនៀលទិន្នា ជាមនុស្សមោហា
ជួជាតិខ្លួនទៅ ៗ
បើអ្នកឯណា វៀរសេពសុរា នោះនឹងបានទៅ
សោយសុខស្ថិតស្ថាន ពិមានសន្ទៅ សឹងតែនិត្យនៅ
និម្មានរតី ៗ
ពីព្រោះប្រាសាទ សាមសិបយោជន៍ស្អាត ប្រកបទីងស្រី
ទេពអប្សរស្ជួតិ គាប់គួរប្រាំបី ពាន់ឆ្នាំទិព្វពីរ
នោះមកកើតជា ៗ
ត្រកូលមហាក្សត្រិយ៍ សេពសោយសម្បត្តិ សម្មតិទេព
ស្តេចស្តែងថ្កើងថ្កាន មែនមានបេស្កា ប្រកបប្រាជ្ញា
បេះបាំងមិគាប់ ៗ
មានចិត្តខ្លាចបាប ខ្លាចពៀរជកប មានស្មារតីខ្ជាប់
ជនប្រាជ្ញប្រុះ ខ្លាសង្ខុះវៃចាប់ ពាក្យពោលគំនាប់
គំនិតសោតជួន ៗ
អំពើទាំងប្រាំ ប្រការចូរចាំ ចិត្តបេះគិតគន់
បង់បញ្ចេវក កម្មជាខ្មួន មិនមានមោះម
ទ្រលទាស់ទោសខ្លុក ៗ

រក្សាសីលប្រាំ　　នេះនៃទីងនាំ　　រូបរួបបានសុខ
ទៀងទាល់និព្វាន　　មិនមានទោតទុក　　ផុតពីនរក
　　សោយសួគ៌សម្បត្តិ　　ៗ
សម្បូណ៌បច្ចុប្បន្ន　　បុណ្យបានទ្រព្យធន់　　ជួនទាំងមនុស្សសត្វ
សិទ្ធិទីស្ថាន　　ស្ថិតប្រាណផុះខាត់　　ខឹងខំកំចាត់
　　កំចាយបាបកម្ម　　ៗ
កម្មពៀរវៀរចេញ　　ចិញ្ចឹមចំណេញ　　ចំណេះចេះចាំ
ចំណោទចោទសួរ　　សមគួរបរិកម្ម　　កម្មដ្ឋានចំណាំ
　　វិបស្សនាហោង　　ៗ